នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២/១៩-០៥-២០២០-អវតក/អជតក(០៤) |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Dec-21, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ**ជាមួយ **ឧបសម្ព័ន្ធសាធារណៈ**ចំនួន១ និង **ឧបសម្ព័ន្ធសម្ងាត់ចំនួន ២៦**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះឯកសារនៅក្នុងសំណុំរឿង ០០៤/២

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence N. MWACHANDE-MUMBA
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហមេធាវី អោ អាន:**
លោក មុំ លុដ្ឋ
លោក Richard ROGERS
លោក Göran SLUITER

**អ្នកទទួលឯកសារ:**
**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក សំ សុគង់
លោកស្រី ស៊ីន សុវ៉ន
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI
លោក ចេត វ៉ាន់លី
លោក គីម ម៉េងឃី
ទី ស្រីនណា
លោក វ៉ែន ពៅ
Laure DESFORGE
Isabelle DURAND
Lyna NGUYEN

# I. សេចក្តីផ្តើម

1. កាលពីដើមខែនេះ ក្នុងពេលបង្ហាញនូវអនុសាសន៍ពីគំនិតផ្តួចផ្តើមផ្សេងៗសម្រាប់មុខងារសេសសល់របស់ អ.វ.ត.ក ចៅក្រម Claudia Fenz បានមានប្រសាសន៍ថា "ដំណាក់កាលសេសសល់ចាប់ផ្តើមដោយខ្លួនឯង ទាំងនៅក្នុងដំណើរការផ្សះផ្សារបស់ជនរងគ្រោះ និងទាំងនៅក្នុងការបំផុសគំនិតក្នុងលក្ខណៈទូលំទូលាយនៃការផ្សះផ្សាជាតិ"[1]។ ចៅក្រម យូ ឧត្តរា បានធ្វើការកត់សំគាល់ថា ដំណាក់កាលសេសសល់ "ទើបតែបានចាប់ផ្តើម" ហើយ "នៅមានកន្លែង និងពេលវេលាដើម្បីរួមចំណែកដល់ដំណើរការនេះ"[2]។

2. ខណៈដែលតុលាការចាប់ផ្តើមធ្វើការផ្លាស់ប្តូរការយកចិត្តទុកដាក់របស់ខ្លួន ទៅលើកិច្ចខិតខំប្រឹងប្រែងសម្រាប់ដំណាក់កាលសេសសល់ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមរម្លឹកថា អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានសម្រេចថា "ការផ្សព្វផ្សាយទូលំទូលាយនៃសម្ភារដែលពាក់ព័ន្ធនឹងកិច្ចដំណើការនីតិវិធីនៅចំពោះមុខតុលាការនេះ [...] គឺត្រូវតែស្របនឹងអាណត្តិរបស់ អ.វ.ត.ក" ហើយ "អាច 'លើកកម្ពស់កិច្ចពិភាក្សាជាសាធារណៈ និងឥតក្លែងក្លាយ អំពីអតីតកាលដែលមានទទ្បឹករណ៍មួយដ៏រឹងមាំ ដើម្បីបន្ថយជាអប្បបរមានូវការបដិសេធ ការមួលបង្កាច់អង្គហេតុ និងការពិតដែលមានតែមួយផ្នែក'"[3]។ សេចក្តីព្រាងយុត្តិសាស្ត្របញ្ចប់របស់ អ.វ.ត.ក បញ្ជាក់យ៉ាងច្បាស់ថា អង្គការសហ

---

[1] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក *សហអ្នករាយការណ៍ស្តីពីមុខងារសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ ផ្តល់របាយការណ៍របស់ខ្លួន* ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១ ("សេចក្តីប្រកាសព័ត៌មានអំពីរបាយការណ៍ស្តីពីមុខងារសេសសល់")។ *សូមមើលផងដែរ* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") សេចក្តីផ្តើម (ទទួលស្គាល់ "ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ")។

[2] សេចក្តីប្រកាសព័ត៌មានអំពីរបាយការណ៍ស្តីពីមុខងារសេសសល់។

[3] សំណុំរឿង ០០១-ឯកសារ **F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ("គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញ") កថាខណ្ឌ ៥ សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ។ ការផ្តល់មូលដ្ឋានអង្គហេតុពិតប្រាកដនឹងជួយផ្តល់អំណាចក្នុងការទាត់ចោលនូវកំហុសផ្សេងៗ និងបដិសេធនិយម ជាពិសេសនៅក្នុងសង្គមបែកបាក់រិះគន់គ្នាក្រោយជម្លោះ។ *សូមមើលឧទាហរណ៍* Diane Orentlicher, *Memories of Judgment (ការចង់ចាំចំពោះសាលក្រម): ការស្ថាបនាកេរដំណែលរបស់តុលាការ ICTY*, 19 Wash. U. Global Stud. L. Rev. (2020), ទំព័រ 316, 318-319, 324 (អ្នករស់រានជីវិតពីហាយនភាព និងជាជ័យលាភីណូបែលសន្តិភាព Elie Wiesel ជឿថា ត្រូវមានករណីកិច្ចក្នុងការថែរក្សានូវការចងចាំរបស់អំពើដ៏រន្ធត់របស់ Third Reich ពីព្រោះវាជាផ្លូវប្រាកដមួយដើម្បីបញ្ឈប់អ្វីដែលណាស៊ីចង់ឲ្យបានសម្រេច គឺការលុបបំបាត់ការចងចាំ ហើយនៅក្នុងការចងចាំនេះ គឺវប្បធម៌តែម្តង)។

ប្រជាជាតិ ("អ.ស.ប") និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា សំខាន់បំផុតធ្វើយ៉ាងណាធានាឲ្យប្រាកដថា បណ្ណសារ អ.វ.ត.ក មិនត្រឹមតែត្រូវបានអភិរក្សស្របនឹងបទដ្ឋានអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង "ផ្តល់លទ្ធភាពចូលពិនិត្យយ៉ាងទូលំទូលាយតាមដែលអាចធ្វើបាន"[4] ផងដែរ។ ដំណើរការនៃការធ្វើចំណាត់ថ្នាក់ឡើងត្រូវបានរំពឹងថា នឹងត្រូវអនុវត្តក្នុងរយៈពេលបីឆ្នាំបន្ទាប់[5]។

3. តម្លាភាពកាន់តែច្រើនចំពោះសំណុំរឿងនៅ អ.វ.ត.ក បំរើឲ្យគោលដៅជាច្រើន។ ក្រៅអំពីការបង្កើនលទ្ធភាពចូលពិនិត្យមើលកំណត់ត្រាប្រវត្តិសាស្ត្រដែលនឹងជួយដល់ការអប់រំ និងការស្រាវជ្រាវអំពីព្រឹត្តិការណ៍នានាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ការធ្វើឲ្យឯកសាររបស់ អ.វ.ត.ក កាន់តែអាចចូលពិនិត្យមើលបានជាសាធារណៈ នឹងជួយបង្ហាញឲ្យឃើញបន្ថែមអំពីភាពជឿជាក់ចំពោះកិច្ចដំណើរការនីតិវិធី[6] អាស្រ័យហេតុនេះវាជួយពង្រឹងដល់កេរដំណែលរបស់តុលាការនេះ។ ជាការបន្ថែម ការបង្កលទ្ធភាពដោយប្រើភាសាខ្មែរចំពោះមតិយោបល់ផ្នែកច្បាប់ និងសាលក្រម សេចក្តីថ្លែងសំអាងដែលមានអំណះអំណាងផ្នែកនីតិវិធី អង្គហេតុ និងអង្គច្បាប់ច្បាស់លាស់ ព្រមទាំងទិដ្ឋភាពនៃការអនុវត្តកិច្ចស៊ើបសួរដែលមានគោលដៅប្រមូលយកនូវភស្តុតាងដែលគួរឲ្យជឿទុកចិត្តបាន នឹងជួយពន្លឿនក្នុងការផ្តល់គុណភាពយុត្តិធម៌ដោយប្រព័ន្ធច្បាប់ជាតិរបស់កម្ពុជា។

4. យ៉ាងណាមិញ ខណៈតម្លាភាព គឺជាគោលបំណងមួយដ៏សំខាន់សម្រាប់មូលហេតុទាំងអស់ខាងលើ វាត្រូវតែមានតុល្យភាពជាមួយនឹងសិទ្ធិ និងផលប្រយោជន៍ផ្សេងទៀត[7]។ ចំណុចដែលសំខាន់បំផុតគឺ

---

[4] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 75/257, U.N. Doc. A/Res/75/257 B, ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ("សេចក្តីព្រាងយុត្តិសាស្ត្របញ្ចប់របស់ អ.វ.ត.ក") មាត្រា ៣(១)។ *សូមមើលផងដែរ* មាត្រា ៣(២)។

[5] សេចក្តីព្រាងយុត្តិសាស្ត្របញ្ចប់ មាត្រា ២(១)។

[6] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២)។

[7] *សូមមើលឧទាហរណ៍* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២), មាត្រា ២៣។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា ៣៣ថ្មី មាត្រា ៣៤ថ្មី។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។ សេចក្តីណែនាំ អនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង, អ.វ.ត.ក/០០៤/២០០៩/វិសោធនកម្មទី២, ដែលបានកែប្រែនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤ ("សេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ") មាត្រា ១.២។ សំណុំរឿង ០០១-ឯកសារ **F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ ៥-៦។ ឯកសារ **D304/12** ដីកាសម្រេចលើសំណើរួមរបស់មេធាវីការពារក្តីសុំធ្វើចំណាត់ឯកសារឡើងវិញចំពោះសេចក្តីសម្រេច និងឯកសារពាក់ព័ន្ធនឹងសំណើសុំធនធាន, ស.ច.ស.អ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦, កថាខណ្ឌ ១៤-១៧។

ការការពារសិទ្ធិរបស់ជនជាប់ចោទ សិទ្ធិរបស់សាក្សីនិងសិទ្ធិរបស់ជនរងគ្រោះ[8]។ កិច្ចការនេះរួមមាន ការការពារសម្ភារសម្ងាត់ផ្ទាល់ខ្លួនមានដូចជា ព័ត៌មានរសើប ឬឯកជន ទាក់ទងនឹងបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត កំណត់ហេតុដែលបង្ហាញឈ្មោះ ឬអត្តសញ្ញាណរបស់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងកំណត់ហេតុដែលបានផលិតឡើងដោយការប្រើអំពើទារុណកម្ម ឬការគំរាមកំហែងធ្វើទារុណកម្ម[9]។

5. ស.ព.អ កត់សំគាល់ថា អ្នកដែលបានផ្តល់កំណត់ហេតុក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរសម្ងាត់របស់ អ.វ.ត.ក មានការរំពឹងទុកអំពីឯកជនភាពពេលពួកគេផ្តល់កំណត់ហេតុ[10]។ ចំពោះសំណុំរឿងដែលមិនបានបញ្ជូនទៅជំនុំជម្រះ ទស្សនៈរបស់ពួកគេអំពីការធ្វើឱ្យព័ត៌មានរបស់ពួកគេទៅជាសាធារណៈ គឺគេមិនដែលគិតទេ ហើយចំពោះការយល់ដឹងរបស់ ស.ព.អ វិញគឺថា ពុំមានធនធានត្រូវបានលៃទុកសម្រាប់ស្វែងរកទស្សនៈរបស់ពួកគេនាពេលអនាគតឡើយ។ ប្រសិនបើការនេះមិនអាចធ្វើបាន ភាគី និងអង្គជំនុំជម្រះដែលទទួលបន្ទុកក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញ មានកាតព្វកិច្ចការពារឱ្យបានត្រឹម

[8] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៤/១-ឯកសារ **D304/6/4** សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, អ.ប.ជ, ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០១៨, កថាខណ្ឌ ២៣។ សំណុំរឿង ០០២-ឯកសារ **E118/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "ចម្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលស្នើសុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង (ឯកសារ E118)" ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១។ *រដ្ឋអាជ្ញា ទល់នឹង Yekatom និង Ngaïssona*, ICC-01/14-01/18, សេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១, កថាខណ្ឌ ៨ (ក្នុងការវាយតម្លៃថាតើឯកសារណាខ្លះអាចដាក់ឱ្យរកបានជាសាធារណៈ ចៅក្រមមួយរូបបានធ្វើការថ្លែងថ្លែងអំពីផលប្រយោជន៍ផ្សេងៗដែលមាននៅចំពោះមុខ ដែលរួមមាន ជាអាទិ៍ គោលការណ៍នៃសាធារណភាព សុវត្ថិភាព សុខុមាលភាពផ្លូវកាយនិងផ្លូវចិត្ត សេចក្តីថ្លៃថ្នូរនិងឯកជនភាពរបស់ជនរងគ្រោះនិងសាក្សី ហើយនឹងសិទ្ធិឯកជនភាពរបស់ជនជាប់ចោទ)។

[9] ការធ្វើឱ្យសម្ភារទាំងនេះទៅជាសាធារណៈអាចនឹងបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗ រួមទាំងស្លាកស្នាមទុយ៌ស ឬជម្លោះនៅក្នុងសហគមន៍ (ជាពិសេស បើសិនជាឯកសារនោះធ្វើការចោទប្រកាន់ប្រឆាំងអ្នកផ្សេងអំពីឥរិយាបថព្រហ្មទណ្ឌ) វិបាកបញ្ច្រាស់ត្រឡប់មករកសមាជិកគ្រួសារដែលមិនបានដឹងអំពីគ្រោះថ្នាក់ដូច្នេះ (រួមទាំង កុមារដែលជាផលនៃការរួមសង្វាសដោយបង្ខំតាមរយៈអាពាហ៍ពិពាហ៍ដោយបង្ខំ) និងផលប៉ះពាល់ដ៏គួរឱ្យភ័យខ្លាចទៅលើឆន្ទៈរបស់សាក្សីនិងជនរងគ្រោះ(សូម្បីតែនៅឯសាលាក្តីដទៃទៀតក៏ដោយ)ក្នុងការប៉ាននិយាយដោយចំហអំពីបញ្ហាឯកជនស្រដៀងគ្នា ទោះជាមានការធានាចំពោះភាពសម្ងាត់ក៏ដោយ។

[10] *Nshogoza ទល់នឹងរដ្ឋអាជ្ញា*, ICTR-2007-91-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ កថាខណ្ឌ ៦៧ ("តុលាការមាន") ផលប្រយោជន៍ក្នុងការការពារបុគ្គលដែលបានយល់ព្រមសហការណ៍ និងផ្តល់កំណត់ហេតុផ្អែកលើគោលការណ៍សម្ងាត់។ សាក្សីសក្តានុពលដែលជាចុងក្រោយមិនបានផ្តល់សក្ខីកម្ម អាចប្រឈមមុខនឹងហានិយភ័យស្រដៀងអ្នកដែលបានផ្តល់ដែរ ឧបមាថា ដោយសារកិច្ចសហការរបស់ពួកគេជាមួយភាគីណាមួយ។ បុគ្គលដែលបានសម្រេចចិត្តមិនផ្តល់សក្ខីកម្មដោយសារតែមានការភ័យខ្លាច ក៏អាចនឹងតម្រូវឱ្យមានអនាមិកផងដែរ គឺអាស្រ័យទៅលើកាលៈទេសៈ")។

ត្រូវនូវសិទ្ធិ និងអត្ថប្រយោជន៍របស់ពួកគេ។ ស.ព.អ សន្និដ្ឋានថា ការនេះគឺរួមបញ្ចូលទាំងការធានាឱ្យប្រាកដថា ព័ត៌មានឯកជនត្រូវបានការពារដូចៗគ្នាសម្រាប់បុគ្គលគ្រប់រូប ដោយពុំគិតអំពីប្រភេទឯកសារ ឬសំណុំរឿង។ ស.ព.អ ទទួលស្គាល់ថា ត្រូវមានការគិតគូរ និងការថែទាំឱ្យបានល្អបំផុតសម្រាប់ដំណើរការនេះ ប៉ុន្តែបុគ្គលដែលបានសហការណ៍ជាមួយ អ.វ.ត.ក ក្នុងការស្វែងរកការពិតសមនឹងទទួលបាននូវការការពារព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានរសើបរបស់ពួកគេ។ តម្លាភាពមិនត្រូវជាអាទិភាពលើអត្ថប្រយោជន៍ទាំងនេះទេ ហើយការគ្រប់គ្រងត្រឹមត្រូវនូវព័ត៌មានដូច្នេះ គឺជាផ្នែកដ៏សំខាន់មួយនៃកេរដំណែលរបស់ អ.វ.ត.ក។

6. ដោយមានការយកចិត្តទុកដាក់ទៅលើសេចក្តីពិចារណាទាំងនេះ និងក្នុងទស្សនៈធ្វើយ៉ាងដើម្បីឱ្យមានការចូលរួមចំណែកប្រកបដោយអត្ថន័យតាំងពីដើមដំបូងតទៅនៅក្នុងដំណើការនៃការធ្វើចំណាត់ថ្នាក់លើឯកសារឡើងវិញ[11] ស.ព.អ បានធ្វើការពិនិត្យឡើងវិញលើឯកសារក្នុងសំណុំរឿង ០០៤/២ ដើម្បីគូសបញ្ជាក់អំពីបញ្ហាមួយចំនួនដែលត្រូវយកមកពិចារណា និងផ្តល់អនុសាសន៍អំពីរបៀបដោះស្រាយបញ្ហាទាំងនោះ។ ខណៈសំណើនេះលើកពីការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារជាក់លាក់នៅក្នុងសំណុំរឿង ០០៤/២ ក៏ពិតមែន តែគោលបំណងជាចំបងនោះគឺ ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍន៍គោលនយោបាយនានាឱ្យបានកាន់តែទូលំទូលាយ ដែលនឹងធានាដល់ការធ្វើចំណាត់ថ្នាក់លើឯកសារឡើងវិញនៅ អ.វ.ត.ក ដែលនឹងអនុវត្តទៅដោយប្រុងប្រយ័ត្ន និងដូចៗគ្នាលើគ្រប់ករណីទាំងអស់។ ក្នុងករណីនេះ សំណើនេះគួរតែត្រូវបានគេមើលឃើញក្នុងន័យប្រទាក់ក្រឡាគ្នាពីសំណើមួយទៀតដែលទើបតែបានដាក់នាពេលថ្មីៗនេះ ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

[11] *សូមមើល* សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, អ.វ.ត.ក/០១/២០០៧/វិសោធនកម្មទី៨, ដែលបានកែប្រែនៅក្នុងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ (“សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ”) មាត្រា ៣.១៤ (“តម្រូវតាមផលប្រយោជន៍យុត្តិធម៌ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលគ្រប់គ្រងសំណុំរឿង អាចដាក់ចំណាត់ប្រភេទឯកសារជាថ្មីក្នុងសំណុំរឿង។ ភាគីជាប់ពាក់ព័ន្ធនឹងត្រូវផ្តល់ឱកាសឱ្យបានដឹង និងធ្វើការឆ្លើយតប មុនមានការធ្វើសេចក្តីសម្រេចបែបនេះ ឬអំឡុងពេលដាក់ចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន ដែលជាការចាំបាច់ក្នុងការការពារព័ត៌មានដែលអាចជាព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត”)។ សេចក្តីប្រកាសព័ត៌មានអំពីរបាយការណ៍ស្តីពីមុខងារសេសសល់ (“នៅមានកន្លែង និងពេលវេលាដើម្បីរួមចំណែកដល់ដំណើរការនេះ:”)។ សំណុំរឿង ០០១-F30/2 ឯកសារ គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ ២-៤។ សំណុំរឿង ០០២-ឯកសារ E467/6 ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងជាឯកសារសាធារណៈ:, អ.ជ.ស.ដ, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩, កថាខណ្ឌ ២។

ក្នុងសំណុំរឿង ០០២/២ ដែលពិភាក្សាអំពីបញ្ហាទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចអនុវត្តបានទៅលើសំណុំរឿង អ.វ.ត.ក ទាំងអស់[12]។

7. ជាចុងក្រោយ បន្ថែមទៅលើការធ្វើចំណាត់ប្រភេទឡើងវិញ ស.ព.អ ទទូចឱ្យ អ.ជ.ត.ក (ឬយន្តការសម្រាប់ការងារនៅសេសសល់ អាស្រ័យលើថាតើសកម្មភាពនឹងត្រូវចាប់ផ្តើមនៅពេលណា) បង្កើតគោលនយោបាយមួយ ដើម្បីគ្រប់គ្រងលើលទ្ធភាពចូលពិនិត្យកំណត់ហេតុទាំងអស់ដែលនៅរក្សាការសម្ងាត់ ឬសម្ងាត់បំផុត បន្ទាប់ពីមានដំណោះស្រាយរបស់អង្គជំនុំជម្រះលើសំណើនេះ ឬសំណើពាក់ព័ន្ធ[13]។ ដោយការបង្កើតនូវគោលការណ៍ណែនាំលម្អិតអំពីយុត្តិកម្មដែលនឹងធានាបានចំពោះលទ្ធភាព និងអំពីគោលបំណងមានកំណត់ដែលឯកសារអាចនឹងត្រូវបានប្រើប្រាស់ នោះ អ.ជ.ត.ក នឹងធានាបានចំពោះភាពស្របគ្នានិងភាពត្រឹមត្រូវយុត្តិធម៌ ក្នុងការគ្រប់គ្រងរដ្ឋបាលលើគោលនយោបាយនេះ។ ដោយរក្សាការអនុវត្តស្របតាមអាណត្តិ និងគោលបំណងរបស់ អ.វ.ត.ក អភិក្រមរួមគប្បីធ្វើយ៉ាងណាឱ្យគោលការណ៍បើកចំហនិងតម្លាភាព មានតុល្យភាពនឹងកាតព្វកិច្ចក្នុងការការពារសន្តិសុខ និងផលប្រយោជន៍ឯកជនភាពរបស់បុគ្គលម្នាក់ៗដែលមានឈ្មោះក្នុងឯកសារទាំងនោះ។

## II. ប្រវត្តិនីតិវិធីពាក់ព័ន្ធ

8. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ស.ព.អ ស្តីទី បានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងសំណុំរឿង ទៅសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ដែលពួកគេក្រោយមកបានបើកសំណុំរឿង ០០៤ និងបានចាប់ផ្តើមធ្វើការស៊ើបសួរទៅលើជនសង្ស័យបីនាក់៖ អ៊ឹម ចាម, អោ អាន និង យឹម ទិត្យ[14]។

---

[12] **សំណុំរឿង ០០២-ឯកសារ** F71 សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១("សំណើសុំការណែនាំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី")។

[13] ស.ព.អ សូមអញ្ជើញ អ.ជ.ត.ក ចូលពិនិត្យគោលនយោបាយនានាដែលនៅជាធរមាននៅត្រង់យន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (*សូមមើល* https://www.irmct.org/sites/default/files/documents/pd-mict-17-160812-en.pdf) តុលាការពិសេសសម្រាប់ការងារសេសសល់សម្រាប់សៀរ៉ាឡេអូន (*សូមមើល* http://www.rscsl.org/Documents/RSCSL%20Access%20Policy.pdf), និងទិន្នន័យកំណត់ហេតុតុលាការឯកភាព (ICTR, ICTY, និង IRMCT) មគ្គុទេសណែនាំសម្រាប់អ្នកប្រើ សម្រាប់ព័ត៌មានលម្អិត (*សូមមើល* https://ucr.irmct.org/manuals/UCR_User_Guide.pdf.)

[14] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។ ឯកសារ **D1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣, ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។

9. នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយបានបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនទៅលើ អ៊ឹម ចែម ស.ច.ស បានបំបែកសំណុំរឿងរបស់គាត់ ចេញពីកិច្ចដំណើរការនីតិវិធីប្រឆាំងជនសង្ស័យនៅក្នុងសំណុំរឿង ០០៤ ផ្សេងទៀត ដោយបង្កើតជាសំណុំរឿង ០០៤/១[15]។ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ ប្រឆាំង អោ អាន និង យឹម ទិត្យ នៅបន្ត។

10. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស.ច.ស បានបំបែកសំណុំរឿង អោ អាន ចេញពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ ទៅលើ យឹម ទិត្យ ដោយបង្កើតជាសំណុំរឿង ០០៤/២ សម្រាប់សំណុំរឿង អោ អាន[16]។

11. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ អ.ជ.ត.ក បានរំលត់សំណុំរឿង ០០៤/២[17]។

12. នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ស.ច.ស បានបង្គាប់ឲ្យបោះត្រា និងដាក់សំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ[18]។

13. នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ អោ អាន បានស្លាប់[19]។

14. នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ (“អ.ប.ជ”) បានថ្លែងថា ស.ច.ស មិនមានសិទ្ធិអំណាចចេញដីកាសម្រេចឲ្យបោះត្រា និងដាក់សំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារទេ ដោយហេតុថា ពួកគេលែងត្រូវបានប្តឹងអំពីសំណុំរឿងនេះទៀតហើយ ក្រោយពីពួក

---

[15] ឯកសារ **D286/7** ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤, ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦។

[16] ឯកសារ **D334/1** ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤, ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

[17] អ.ជ.ត.ក០៤/២ ពិសេស-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០, កថាខណ្ឌ ៧១(vi)។

[18] ឯកសារ **D363/3** ដីកាបង្គាប់ឲ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ, ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០, កថាខណ្ឌ ១០។

[19] The Phnom Penh Post (ឌឹភ្នំពេញប៉ុស្តិ៍), *អោ អាន របស់ខ្មែរក្រហម ស្លាប់ហើយ*, ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២០។ Cambodia News English (ព័ត៌មានកម្ពុជាភាសាអង់គ្លេស), *មន្ត្រីខ្មែរក្រហម អោ អាន ស្លាប់ហើយនៅបាត់ដំបង*, ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២០។

គាត់បានចេញដីកាដំណោះស្រាយរបស់ពួកគេ។ ចៅក្រមអន្តរជាតិបានថ្លែងថាការិយាល័យតុលាការចុងក្រោយដែលត្រូវបានប្តឹងអំពីសំណុំរឿង ០០៤/២ បើមិន អ.ប.ជ គឺ អ.ជ.ត.ក[20]។

15. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានច្រានចោលសំណើសុំវិធានការការពារទាំងអស់ ដែលធ្វើឡើងដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២[21]។

16. នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ អ.ប.ជ បានធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារនៅក្នុងសំណុំរឿង ០០៤ និង ០០៤/១[22] ដែលភាគច្រើននៃឯកសារទាំងនោះមានចំណែក និង/ឬ ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៤/២។ ក៏ប៉ុន្តែ អ.ប.ជ មិនបានចេញសេចក្តីសម្រេចអំពីការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារដែលឆ្លើយតបនៅក្នុងសំណុំរឿង ០០៤/២ ទេ ដូច្នេះនេះសបញ្ជាក់ថា ខ្លួនបានពិចារណាថា អ.ជ.ត.ក គឺជាអង្គជំនុំជម្រះតែមួយគត់ដែលមានគុណវុឌ្ឍិ នៅក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារក្នុងសំណុំរឿង ០០៤/២។ ជាលទ្ធផល សេចក្តីថ្លែងសំអាងជាច្រើនដែលជាប់ពាក់ព័ន្ធយ៉ាងជាក់លាក់ជាមួយ អោ អាន អាចរកបានជាសាធារណៈនៅលើសំណុំរឿងទាំងនេះដែលពាក់ព័ន្ធនឹង អ៊ឹម ចែម និង/ឬ យឹម ទិត្យ ប៉ុន្តែមិនមាននៅក្នុងសំណុំរឿង អោ អាន[23]។

---

[20] សំណុំរឿង ០០៣-ឯកសារ **D266/27 & D267/35** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១, កថាខណ្ឌ ១៣៣ (*សូមមើលផងដែរ* កថាខណ្ឌ ១២៦, ១៣២)។

[21] ឯកសារ **D348** ដីកាសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។

[22] សំណុំរឿង ០០៤-ឯកសារ **D387** អង្គបុរេជំនុំជម្រះអនុស្សរណៈអន្តរការិយាល័យចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ (ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញបាន ៥០៩ ឯកសារ ដូចមានចែងនៅក្នុង ឯកសារ **D387.1** ឧបសម្ព័ន្ធ)។ សំណុំរឿង ០០៤/១-ឯកសារ **D317** អង្គបុរេជំនុំជម្រះអនុស្សរណៈអន្តរការិយាល័យចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤/១, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ (ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញបាន ២៧៣ ឯកសារ ដូចមានចែងនៅក្នុង ឯកសារ **D317.1** ឧបសម្ព័ន្ធ)។

[23] ជាឧទាហរណ៍ ឯកសារដូចតទៅនេះត្រូវបានធ្វើចំណាត់ថ្នាក់ សម្ងាត់ នៅក្នុងសំណុំរឿង ០០៤/២ និងជាសាធារណៈនៅក្នុងសំណុំរឿង ០០៤/១៖ ឯកសារ **D282/4** លិខិតឆ្លើយតបរបស់ អោ អាន ទៅនឹងលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពីការដាក់ខ្សែអាត់សំឡេងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅក្នុងឃ្លាំងផ្ទុកឯកសាររួម, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥។ ឯកសារ **D284/1/1** សំណើសុំការអនុញ្ញាតដើម្បីដាក់ជាភាសាអង់គ្លេសមុននូវ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើ ការឆ្លើយតបរបស់ អោ អាន ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦។ ឯកសារ **D258/1/2** ការដកសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើពាក្យសុំមោឃភាពបទចោទនៃអំពើមនុស្សឃាតគិតទុកជាមុន និងកិច្ចស៊ើបសួរពាក់ព័ន្ធ អនុលោមតាម វិធាន ៧៦ នៃវិធានផ្ទៃក្នុង របស់

## III. ច្បាប់ជាធរមាន និង គោលការណ៍ណែនាំ

17. កិច្ចព្រមព្រៀង អ.វ.ត.ក ចែងថាៈ

អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ។ ក្នុងផលប្រយោជន៍ធានាឱ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងទុកចិត្តបាន ត្រូវយល់ថា តំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្ដាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្ដាប់ការជំនុំជម្រះក្ដីបានគ្រប់ពេលវេលាទាំងអស់។ ការលើកលែងមិនឱ្យចូលរួមស្ដាប់ការជំនុំជម្រះក្ដីនេះតាមមាត្រា១៤ នៃអនុសញ្ញាអាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែនៅពេលណា ដែលការផ្សព្វផ្សាយចេញទៅនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌[24]។

18. វិធានផ្ទៃក្នុងណែនាំថាៈ

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមានត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និងជនរងគ្រោះដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង[25]។

19. សេចក្ដីណែនាំអនុវត្តន៍ស្ដីទីការធ្វើចំណាត់ប្រភេទឯកសារចែងថាៈ

---

អោ អាន ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥។ ឯកសារ **D260/1/1/1** សំណើសុំការអនុញ្ញាតដើម្បីដាក់ជាភាសាអង់គ្លេស នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេច លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៥ របស់ អោ អាន ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥។

[24] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២)។

[25] វិធានផ្ទៃក្នុង ២១(១)។

គោលការណ៍ដែលណែនាំឲ្យមានសេចក្តីណែនាំនេះ គឺជាតម្រូវការទាមទារឲ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហរដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរដំណែល[26]។

ឯកសារ ឬព័ត៌មានអាចត្រូវចាត់ប្រភេទសារឡើងវិញ(និងដាក់ទៅក្នុងផ្នែកនៃសំណុំរឿងដែលមានកម្រិតសម្ងាត់ខុសគ្នា) អនុលោមតាមបទបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះតាមករណីសមស្រប[27]។

ការិយាល័យតុលាការចុងក្រោយដែលទទួលបានសំណុំរឿង ត្រូវធ្វើការពិនិត្យឡើងវិញចំពោះឯកសារស្តីពីសុវត្ថិភាពនៃការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញនៅក្នុងសំណុំរឿង [...] សេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារ ដែលមិនបានធ្វើឡើងដោយស្ថាប័នតុលាការចុងក្រោយដែលជាអ្នកទទួលសំណុំរឿងទេនោះ ត្រូវតែធ្វើឡើងដោយ ឬទៅតាមបរិបទនៃយន្តការដែលមាន[28]។

20. បន្ទាប់ពីសំណុំរឿង ០០១ បានបិទបញ្ចប់ អ.ជ.ត.ក បានចេញសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ដោយបញ្ជាក់ថា៖

អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថាការធ្វើចំណាត់ថ្នាក់លើឯកសារត្រូវធ្វើឡើងដោយធ្វើយ៉ាងណាឲ្យមានតុល្យភាពរវាងតម្រូវការរក្សាការសម្ងាត់ និងតម្រូវការនៃតម្លាភាពដែលកើតចេញពីគោលការណ៍ជាសារវន្ត ដែលគ្រប់គ្រងលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាលើគោលបំណងរបស់តុលាការក្នុងការអប់រំ និងរក្សាកេរតំណែល។ ដូច្នេះ អង្គជំនុំជម្រះនេះសូមរំលឹកឡើងវិញថា 'ការចែកចាយឲ្យបានទូលំទូលាយនូវសម្ភារៈពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ [...] គឺស្រប ទៅនឹងអាណត្តិរបស់ អ.វ.ត.ក ដែលរួមមានទាំងការចូលរួមចំណែកនៅក្នុងការផ្សះផ្សា

[26] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ១.២។

[27] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ៩.១។ *សូមមើលផងដែរ* សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៣.១៤។

[28] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ១២.២, ១២.៤ (គូសបញ្ជាក់បន្ថែម)។

ជាតិ និងការផ្តល់ឲ្យនូវឯកសារដើម្បីគាំទ្រដល់ការស្វែងរកការពិតខាងផ្នែកប្រវត្តិសាស្ត្រដ៏យូរអង្វែងមកហើយ'។ ការចែកចាយភ័ស្តុតាងសំខាន់ៗជាច្រើនដែលមាននៅក្នុងសំណុំរឿង ០០១ អាចជម្រុញឲ្យមាន 'កិច្ចពិភាក្សាលើអតីតកាលជាសាធារណៈ និងដោយមិនមានការលាក់លៀម ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំមួយដែលជាលទ្ធផល អាចកាត់បន្ថយនូវទស្សនៈនៃការមិនទទួលស្គាល់ ការបំភ្លៃអង្គហេតុ និងការពិតដែលមានតែមួយផ្នែកនោះបាន'[29]។

21. ពាក់ព័ន្ធដោយផ្អែកទៅនឹងរឿងក្តីនានាដែលមិនបានបន្តទៅជំនុំជម្រះ ត្រូវបាន អ.ជ.ត.ក យល់ឃើញថា៖

> ឯកសារដែលមានតម្លៃជាច្រើននៅក្នុងសំណុំរឿង ត្រូវបានប្រមូលនៅក្នុងអំឡុងពេលដំណើរការកិច្ចស៊ើបសួរ។ ដោយហេតុថាកិច្ចដំណើរការនីតិវិធី [...] បានបញ្ចប់រួចហើយ ការដកចំណាត់ថ្នាក់ឯកសារដែលពាក់ព័ន្ធកិច្ចស៊ើបសួរ លែងមានហានិភ័យជាទូទៅនៃការប៉ះពាល់លើសិទ្ធិរបស់ជនជាប់ចោទ ឬសុចរិតភាពនៃកិច្ចស៊ើបសួរ។ [...] នៅក្នុងពេលជាមួយគ្នានេះ ដោយពិចារណាឃើញថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នៅកំពុងដំណើរការនៅឡើយ ហើយបន្ទាប់ពីបញ្ចប់កិច្ចដំណើរការនីតិវិធីនេះ ការសម្ងាត់ចំពោះសំអាងមួយចំនួន អាចនៅតែរក្សាទុក [...][30]។

22. សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្តីពីការធ្វើចំណាត់ប្រភេទឯកសារទទួលស្គាល់ថា ព័ត៌មានមួយចំនួនបន្តតម្រូវឲ្យមានការដោះស្រាយដោយប្រុងប្រយ័ត្ន ក្រោយពីកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់។ វាផ្តល់ការការពារជាក់លាក់ចំពោះសំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ (រួមទាំងការវាយតម្លៃរបស់អង្គភាពគាំពារសាក្សី/អ្នកជំនាញ ("WESU")) ឯកសារ និងព័ត៌មានដែលស្ថិតក្រោមវិធានការការពារ និងព័ត៌មានទាក់ទងនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ[31]។ វាក៏បានចែងផងដែរថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ("CPA") ដែលត្រូវបានបដិសេធមិនឲ្យចូលរួមក៏ត្រូវនៅរក្សាការសម្ងាត់ផងដែរ ចំណែកឯព័ត៌មានលម្អិតនៅក្នុងពាក្យបណ្តឹង

---

[29] សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ៥ យោងខាងក្នុងត្រូវបានលុប។

[30] សំណុំរឿង ០០១-**F30/2** គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ៦។

[31] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា៦ (ចែងថា "ជាគោលការណ៍ ឯកសារ និងព័ត៌មានក្នុងចំណាត់ថ្នាក់ដូចខាងក្រោមជាឯកសារនិងព័ត៌មានសម្ងាត់ លើកលែងតែមានចំណាត់ថ្នាក់ផ្សេងដោយសេចក្តីសម្រេចរបស់តុលាការ")។

របស់ជនរងគ្រោះ និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានអនុញ្ញាតទទួលយកនោះ ត្រូវតែកោសលុប ប្រសិនបើឯកសារទាំងនោះត្រូវបានធ្វើឲ្យទៅជាសាធារណៈ[32]។

23. ភាពចាំបាច់ក្នុងការការពារភាពឯកជនរបស់ជនរងគ្រោះ និងព័ត៌មានផ្ទាល់ខ្លួនដែលមិនចង់ឲ្យគេដឹងឮអំពី ក៏ត្រូវបានតម្កល់នៅក្នុងសេចក្តីណែនាំរបស់អគ្គលេខាធិការ អ.ស.ប ផងដែរ សម្រាប់ការធ្វើចំណាត់ប្រភេទ និងការដោះស្រាយចំពោះព័ត៌មានដែលមិនចង់ឲ្យគេដឹងឮអំពី[33] និងនៅក្នុងសេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច ដែលត្រូវបានអនុម័តដោយមហាសន្និបាត[34]។ សេចក្តីប្រកាសនេះចែងថា៖

> ជនរងគ្រោះគួរទទួលបានការប្រព្រឹត្តដោយក្តីករុណា និងសេចក្តីគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ពួកគេ។ [...]
>
> ភាពអើពើនៃដំណើរការតុលាការ និងរដ្ឋបាលចំពោះតម្រូវការរបស់ជនរងគ្រោះ គួរត្រូវបានសម្របសម្រួលដោយ [...] ការចាត់វិធានការក្នុងការកាត់បន្ថយភាពរំខានចំពោះជន

[32] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ៧.២, ៧.៤។ ស.ព.អ ទទួលស្គាល់ថា ស.ច.ស យល់ឃើញផ្សេង ទាក់ទងនឹងភាពអាចទទួលយកបាននៃសម្ភារៈទាំងអស់នេះ ប៉ុន្តែដូចបានលើកឡើងក្នុងឯកសារ **D362/6** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ("សេចក្តីពិចារណារបស់ អ.ប.ជ លើភាពអាចទទួលយកបាន") យោបល់របស់ចៅក្រម Baik និង Beauvallet ("យោបល់របស់ចៅក្រមអន្តរជាតិ") កថាខណ្ឌ ១១៨ ការបរាជ័យរបស់ អ.ប.ជ ក្នុងការឈានទៅដល់សំឡេងភាគច្រើនលើសលុបលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ស.ច.ស.អ មានន័យថា ដីកាមានសុពលភាព ។

[33] *សូមមើល ឧទាហរណ៍* ព្រឹត្តិប័ត្ររបស់អគ្គលេខា "ព័ត៌មានដែលមិនចង់ឲ្យគេដឹងឮអំពី ការធ្វើចំណាត់ប្រភេទ និង ការដោះស្រាយ" ST/SGB/2007/6, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ ផ្នែក ១.២ ("ព័ត៌មានដែល គេជឿជាក់ថា មិនចង់ឲ្យគេដឹងឮអំពីរួមមានដូចខាងក្រោម [...] ឯកសារទាំងឡាយណាដែលការដាក់បង្ហាញរបស់ពួកវា អាចនឹងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាព ឬសន្តិសុខរបស់បុគ្គលណាម្នាក់ រំលោភសិទ្ធិរបស់គាត់ ឬបំពានលើភាពឯកជនរបស់គាត់។ [...] ព័ត៌មានប្រភេទផ្សេងទៀត ដោយហេតុថា ខ្លឹមសាររបស់ពួកវា ឬកាលៈទេសៈនានានៃការបង្កើតឯកសារនោះ ឬការប្រាស្រ័យទាក់ទងត្រូវតែរក្សាជាសម្ងាត់។")។ ព្រឹត្តិប័ត្ររបស់អគ្គលេខា "សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ៖ ព័ត៌មានដែលមិនចង់ឲ្យគេដឹងឮអំពី ការធ្វើចំណាត់ប្រភេទ ការដោះស្រាយ និងការចូលមើល" ST/SGB/2012/3, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ផ្នែក ៤.២ ("បន្ថែមលើឯកសារ និង ព័ត៌មាន ដែលបានកំណត់អត្តសញ្ញាណថាមិនចង់ឲ្យគេដឹងឮ នៅក្នុង ST/SGB/2007/6 ឯកសារ និងព័ត៌មានដែលមិនចង់ឲ្យគេដឹងឮ ត្រូវរួមបញ្ចូលដូចខាងក្រោម៖ [...] ឯកសារដែលមានព័ត៌មានដែល ប្រសិនបើដាក់បង្ហាញមិនមានការអនុញ្ញាតត្រឹមត្រូវ អាចបង្ហាញអត្តសញ្ញាណរបស់សាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀតដែលត្រូវការពារ។")។

[34] សេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច ត្រូវបានអនុម័តដោយ UN G.A. Res. 40/34, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។

រងគ្រោះ ការពារភាពឯកជនរបស់ពួកគេ នៅពេលចាំបាច់ និងធានាសុវត្ថិភាពរបស់ពួកគេ ក៏ដូចជាសុវត្ថិភាពរបស់គ្រួសាររបស់ពួកគេ និងសាក្សីនានាក្នុងនាមពួកគេ មិនឲ្យមានការគំរាមកំហែង និងការសងសឹក [។][35]

24. សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ ដែលបានឈានដល់មុខងារសេសសល់ បានបង្កើតគោលការណ៍ចូលមើលផ្លូវការ ដើម្បីធានាថា ផលប្រយោជន៍នានាត្រូវបានថ្លឹងថ្លែងត្រឹមត្រូវ និងត្រូវបានគោរពយ៉ាងស៊ីចង្វាក់។ នៅតុលាការពិសេសសម្រាប់ការងារសេសសល់សម្រាប់សៀរ៉ាឡេអូន ("RSCSL") គោលការណ៍ចូលមើលនេះចែងថាៈ

> ការងាររបស់ RSCSL ត្រូវតែមានលក្ខណៈបើកចំហរ និងតម្លាភាព លើកលែងតែក្នុងកម្រិតដែលថា សភាពនៃឯកសារ និងព័ត៌មានដែលពាក់ព័ន្ធ មានលក្ខណៈមិនចង់ឲ្យគេដឹងឮអំពី [...]។ សម្រាប់គោលបំណងនៃគោលការណ៍នេះ និងស្របទៅនឹងគោលការណ៍ស្តីពីឯកសារ និងបណ្ណសាររបស់ RSCSL ឯកសារនិងព័ត៌មានដែលមិនចង់ឲ្យគេដឹងឮអំពី គួររួមបញ្ចូល [...] ឯកសារ និងព័ត៌មានទាក់ទងនឹងការការពារសាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀត ដែលបានយោងនៅក្នុងភ័ស្តុតាង ឬម្យ៉ាងវិញទៀត ទាក់ទងទៅនឹងដំណើរការតុលាការ រួមមាន ឯកសារដែលមានព័ត៌មានដែលប្រសិនបើដាក់បង្ហាញដោយមិនមានការអនុញ្ញាតត្រឹមត្រូវអាចបង្ហាញអត្តសញ្ញាណ និងទីកន្លែងរបស់សាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀតដែលត្រូវការពារ[36][។]

គោលការណ៍ចូលមើលសម្រាប់ឯកសារដែលតម្កល់ ដោយយន្តការសេសសល់អន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌ ចែងថា ព័ត៌មានដែល*រួចផុត*ពីការដាក់បង្ហាញរួមមានៈ

> កំណត់ហេតុ និងព័ត៌មានដែលការដាក់បង្ហាញរបស់ពួកវាអាចនឹងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាព ឬសន្តិសុខរបស់បុគ្គលណាម្នាក់ រំលោភលើសិទ្ធិរបស់គាត់ ឬបំពានលើភាពឯកជនរបស់គាត់។ ចំណុចនេះត្រូវរួមបញ្ចូលទាំងឯកសារនិងព័ត៌មានដែលទាក់ទងនឹងការការពារសាក្សី ជនរងគ្រោះ និងបុគ្គល

---

[35] សេចក្តីប្រកាស អំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃ ឧក្រិដ្ឋកម្ម និងការរំលោភអំណាច កថាខណ្ឌ ៤, ៦។

[36] តុលាការពិសេសដែលនៅសេសសល់សម្រាប់សៀរ៉ាឡេអូនៈ ឯកសារ និងព័ត៌មានដែលមិនចង់ឲ្យគេដឹងឮអំពី ការធ្វើចំណាត់ប្រភេទ ការផ្លាស់ប្តូរក្នុងការធ្វើចំណាត់ប្រភេទនិងគោលការណ៍ចូលមើល តុលាការពិសេសដែលនៅសេសសល់សម្រាប់សៀរ៉ាឡេអូន ("គោលការណ៍ចូលមើលរបស់ RSCSL") ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ ផ្នែ ៤.១, ៤.២(ខ)។

ដែលងាយរងគ្រោះផ្សេងទៀត ដែលត្រូវបានយោងនៅក្នុងភស្តុតាង ដែលបានបង្ហាញនៅចំពោះមុខតុលាការ ICTR, ICTY ឬ យន្តការ ឬ ម្យ៉ាងវិញទៀត ទាក់ទងនឹងដំណើរការតុលាការ រួមមានឯកសារដែលមានព័ត៌មានដែល ប្រសិនបើដាក់បង្ហាញ ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ នឹងបង្ហាញអត្តសញ្ញាណ និងទីកន្លែងរបស់សាក្សី ជនរងគ្រោះ និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀតដែលត្រូវការពារ។ ចំណុចនេះក៏ត្រូវបញ្ចូលផងដែរនូវព័ត៌មានផ្ទាល់ខ្លួន ដែលពាក់ព័ន្ធទៅនឹងបុគ្គល គ្រួសាររបស់បុគ្គល ដែលត្រូវបាន ឬកំពុងឃុំខ្លួនដោយតុលាការ ICTR, ICTY ឬ យន្តការ[37]។

25. ស្រដៀងគ្នានេះ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (“TSGM”) ធ្វើតុល្យភាពចំពោះផលប្រយោជន៍ដែលប្រគួតប្រជែងគ្នា ដោយបានធ្វើឱ្យឯកសារជាច្រើនក្នុងបណ្ណសាររបស់ខ្លួនអាចចូលមើលបានជាសាធារណៈ ប៉ុន្តែដោយមានការការពារយ៉ាងខ្ពស់ចំពោះព័ត៌មានរសើប[38]។ ឧទាហរណ៍ ការស្រាវជ្រាវតាមអនឡាញរកឈ្មោះអ្នកជាប់ឃុំឃាំងណាម្នាក់ នឹងផលិតបាននូវបញ្ជីមួយនៃឯកសារបណ្ណសារទាំងអស់ដែលទាក់ទងនឹងអ្នកជាប់ឃុំឃាំងនោះ ប៉ុន្តែអ្នកស្រាវជ្រាវមិនអាចមើលខ្លឹមសាររបស់នៃឯកសារណាមួយបានទេ ដូចជាចម្លើយសារភាព ឬប្រវត្តិរូប ដែលយើងសន្មតថាត្រូវបានផលិតឡើងក្រោមអំពើទារុណកម្ម ឬការគំរាមកំហែងនៃអំពើទារុណកម្ម។ អ្នកស្រាវជ្រាវនឹងត្រូវបានពញ្ញាក់អារម្មណ៍អំពីអត្ថិភាពនៃកំណត់ហេតុទាំងនេះ ប៉ុន្តែមុននឹងត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលឯកសារទាំងនេះ គាត់ត្រូវដាក់ពាក្យសុំការអនុញ្ញាតនិងបំពេញលក្ខខណ្ឌតម្រូវមួយចំនួនដូចមានចែងក្នុងគោលនយោបាយរបស់សារមន្ទីរស្តីពីសិទ្ធិចូលពិនិត្យមើលឯកសារជាមុនសិន។ TSGM បានចែងយ៉ាងច្បាស់នៅលើគេហទំព័ររបស់ខ្លួនថា៖

> ព័ត៌មានដែលមាននៅក្នុងឯកសារទាំងនេះភាគច្រើន ត្រូវបានទាញយកតាមរយៈការធ្វើទារុណកម្ម ឬក្រោមការគំរាមកំហែងនៃអំពើទារុណកម្ម។ ជាវិបាក មតិយោបល់ ឬកំណត់ហេតុនៅក្នុងឯកសារទាំងនេះ ត្រូវតែបំពេញកិច្ចដោយមានការដោយប្រុងប្រយ័ត្នខ្ពស់បំផុត ដោយមិនត្រូវទទួលយកជាអង្គហេតុនិងមិនអាចទទួលយកបានជាភស្តុតាងនៅក្នុងតុលាការទេ បើតាមច្បាប់នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម។ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង មិនអាចដាក់

---

[37] គោលការណ៍ចូលមើលសម្រាប់ឯកសារតម្កល់ដោយយន្តការសម្រាប់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ យន្តការសេសសល់សម្រាប់សាលាក្តីឧក្រិដ្ឋកម្ម, MICT/17/វិ១ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ (“គោលការណ៍ចូលមើលសម្រាប់ IRMCT”) មាត្រា ១០(៣)(ខ)។ *សូមមើលផងដែរ* មាត្រា ៧(២)។

[38] ដូចបានពិភាក្សាដោយសង្ខេបនៅក្នុងជើងទំព័រ ៩ ខាងលើ។

ឲ្យស្ថិតក្រោមការទទួលខុសត្រូវចំពោះការប្រើប្រាស់ ឬពឹងផ្អែកលើមតិយោបល់ របកគំហើញ និង ទិន្នន័យនៅក្នុងឯកសារទាំងនេះឡើយ[39]។

## IV. វិធីសាស្ត្រនៃការវិភាគ

26. ដើម្បីដឹកនាំអនុវត្តលើការងារត្រួតពិនិត្យឲ្យបានលម្អិត ស.ព.អ បានទទួលបញ្ជីសារពើព័នសាយឡាប (Zylap) នៃសំណុំរឿង ០០៤/២ ពីអង្គភាព CMS ក្នុងទម្រង់ស្រេដស៊ីតដែលអាចជ្រើសតាមប្រភេទបាន ជាទិន្នន័យដែលផ្តល់ព័ត៌មាននៅក្នុងទិន្នន័យផ្សេងទៀត (metadata) ចំពោះឯកសារនីមួយៗ។ បញ្ជីសារពើព័នសាយឡាប ក៏បង្ហាញផងដែរអំពីចំនួនភ័ស្តុតាង - នៅក្នុងសំណុំរឿង ០០៤/២ គឺមាន ៣៥,៦០៦ ឯកសារ នៅក្នុងសំណុំរឿងនេះ។ យ៉ាងណាមិញ តួរលេខនេះឆ្លុះបញ្ចាំងអំពីកំណត់ហេតុគ្រប់ភាសាទាំងបី ដូច្នេះចំនួនឯកសារនីមួយៗគឺមានចំនួនតិចជាងយ៉ាងច្រើននៃចំនួនសរុប។ និយាយម្យ៉ាងទៀតថា ប្រសិនបើឯកសារ ក ត្រូវបានបកប្រែពីភាសាខ្មែរទៅភាសាពីរទៀតគឺ អង់គ្លេស និង បារាំង នោះវារាប់ចំនួននេះថា បីឯកសារ នៅក្នុងសាយឡាប ជាជាងរាប់ថា មួយ ចំណែកឯកសារ ខ ដែលបានបកប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេសតែមួយ នឹងរាប់ថាពីរ។ សំណើនេះនឹងរក្សាប្រព័ន្ធនៃការរាប់នេះ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ ដោយសារប្រព័ន្ធសារពើព័នសាយឡាប គឺជាមូលដ្ឋាននៃការវិភាគរបស់ ស.ព.អ។ ក្នុងចំណោមឯកសារទាំង ៣៥,៦០៦ ក្នុងសំណុំរឿង ០០៤/២ មានឯកសារចំនួន ២,១៣២ ត្រូវបានធ្វើចំណាត់ថ្នាក់ថា សាធារណៈ ចំណែកឯ ៣៣,៤២១ ឯកសារទៀត ត្រូវបានធ្វើចំណាត់ថ្នាក់ថា សម្ងាត់ និងឯកសារចំនួន ៥៣ ថា សម្ងាត់បំផុត។

27. ឯកសារនៅក្នុងសំណុំរឿងនេះ ត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមជំពូក "ប្រភេទកំណត់ហេតុ" នៅក្នុងសាយឡាប និងដើម្បីងាយស្រួលក្នុងការយោង ការវិភាគរបស់ ស.ព.អ សូមយោងទៅរកឯកសារទាំងនេះតាមជំពូកទាំងនោះ[40]។ យ៉ាងណាមិញ ឯកសារប្រភេទជាច្រើនទៀតអាចនឹងរកបាននៅក្នុងជំពូកប្រភេទកំណត់ហេតុតែមួយ ដូច្នេះវាមិនល្អទេបើសិនជាសេចក្តីសម្រេចអំពីការធ្វើចំណាត់ថ្នាក់ឡើងវិញក្រសោមយកទាំងអស់ដោយផ្អែកលើការបង្កើតគំរូតែមួយនេះ។ ឧទាហរណ៍ ប្រភេទកំណត់ហេតុជា "របាយការណ៍" រួមបញ្ចូល របាយការណ៍ស៊ើបអង្កេតដែលគ្របដណ្តប់ទាំងផលប្រយោជន៍ផ្សេងៗជាច្រើនដែលទទួលបានការការពារ ក៏ដូចជារបាយការណ៍សម័យកម្ពុជាប្រជាធិបតេយ្យដែលបង្ហាញថាមិនមានបញ្ហាក្នុងការការពារជាបន្ត។

---

[39] *សូមមើល* http://archives.tuolsleng.gov.kh/documents, សេចក្តីថ្លែងអំពីការបោះបង់ការទាមទារ។

[40] ឧបសម្ព័ន្ធ ក ផ្តល់ព័ត៌មានលម្អិតនៃឯកសារសំណុំរឿង ០០៤/២ តាមប្រភេទកំណត់ហេតុ ហើយក្នុងប្រភេទនីមួយ គឺទៅតាមចំណាត់ថ្នាក់ (សាធារណៈ សម្ងាត់ សម្ងាត់បំផុត)។

28. ជាការបន្ថែម ប្រព័ន្ធកំណត់ជំពូកឯកសារតាម "ប្រភេទកំណត់ហេតុ" អាចរារាំងដល់ការយល់ដឹងច្បាស់លាស់អំពីទំនាក់ទំនងរវាងឯកសារដែលមានលក្ខណៈជាក់ស្តែង នៅពេលរើសតាមប្រភេទ និងតាមការសម្រាំងនៅក្នុងស្រ្តេដស៊ីដតាមរបៀបផ្សេង។ ឧទាហរណ៍ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (CPA) មួយអាចត្រូវបានចាត់ចូលក្នុងជំពូក "Victims Application" (ពាក្យសុំរបស់ជនរងគ្រោះ) ខណៈដែលសេចក្តីសង្ខេបនៃ CPA នោះត្រូវបានកំណត់ថា"របាយការណ៍" ហើយព័ត៌មានបន្ថែមគឺជា "Letter" (លិខិត)។ ការដាក់ឯកសារតាមលំដាប់លេខរៀងបង្ហាញឱ្យឃើញថាប្រភេទកំណត់ហេតុទាំងបីពាក់ព័ន្ធអ្នកដាក់ពាក្យសុំតែមួយដដែល។ ការណ៍នេះវាជួយនៅក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញឱ្យកាន់តែស្របគ្នា៖ ប្រសិនបើឯកសារមួយត្រូវបានធ្វើឱ្យទៅជាសាធារណៈ ឬ តម្រូវឱ្យធ្វើការកោសលុប ឯកសារដែលពាក់ព័ន្ធទំនងជាទទួលបានការបំពេញកិច្ចដូចគ្នា[41]។

29. ដើម្បីរៀបចំព័ត៌មានឱ្យកាន់តែងាយស្រួលសម្រាប់ការវិភាគ ស.ព.អ បានប្រមូលដាក់ជាក្រុមទៅជាប្រាំជំពូកធំៗនូវប្រភេទកំណត់ តាមការចាត់តាំងដោយប្រព័ន្ធសាយឡាប។ ជំពូកទាំងនេះត្រូវបានវាយឈ្មោះដូចខាងក្រោមជាអក្សរដិតធំ ហើយប្រភេទកំណត់ហេតុនៅក្នុងជំពូកនីមួយៗមានការកត់សំគាល់នៅក្នុងវង់ក្រចក៖

ក) **DK-era documents (ឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យ)** (សេចក្តីថ្លែងការជាសាធារណៈកំណត់ហេតុនៃកិច្ចប្រជុំ របាយការណ៍ សារទូរលេខ បញ្ជីអ្នកទោស ប្រវត្តិរូប ចម្លើយសារភាព សៀវភៅកំណត់ត្រា អត្ថបទសារព័ត៌មាន (ផ្នែក ១) បទបញ្ជា និងវិធានផ្ទៃក្នុង)។

ខ) **Pleadings (សារណា)** (ញត្តិស្នើសុំ សំណើ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ចម្លើយតប ការឆ្លើយតប សេចក្តីសម្រេច ដីកាសម្រេច សាលក្រម កំណត់ហេតុនៃបណ្តឹងឧទ្ធរណ៍)[42]។

---

[41] អាស្រ័យហេតុនេះ ការវិភាគរបស់ ស.ព.អ រៀបចំព័ត៌មានដាក់តាមក្រុមតាមលេខរៀងដើម្បីឱ្យទំនាក់ទំនងនៃឯកសារមានលក្ខណៈកាន់តែច្បាស់ចំពោះសារណា សម្ភាររបស់សាក្សី និងសម្ភាររបស់ជនរងគ្រោះនិងភាគីដើមបណ្តឹងរដ្ឋប្បវេណី។

[42] បញ្ជីឯកសារដែល ស.ព.អ ស្នើឱ្យដាក់ជាសាធារណៈគឺត្រូវបានបែងចែកជាឧបសម្ព័ន្ធចំនួនពីរ។ ឧបសម្ព័ន្ធ ខ (សារណា) ដែលមានបញ្ជីឯកសារទាក់ទងនឹងសារណាផ្សេង (សំណើសុំ ញត្តិ ។ល។) ត្រូវបាននិងកំពុងស្នើសុំការធ្វើចំណាត់ថ្នាក់ឡើងវិញនៅក្នុងសំណើនេះផងដែរ។ ឧបសម្ព័ន្ធ ឃ-៥ មានបញ្ជីឯកសារដែលនៅសល់ និងវៀវលែងតែមានការកត់សំគាល់ផ្សេងពីនេះ គឺវាពាក់ព័ន្ធទៅនឹងសារណាដែលបានធ្វើចំណាត់ថ្នាក់ជាសាធារណៈរួចហើយនៅក្នុងសំណុំរឿង ០០៤/២។

គ) **Documents relating to the investigative process** (**ឯកសារពាក់ព័ន្ធនឹងដំណើរការស៊ើបសួរ**) (លិខិត អនុស្សរណៈ ដីកាចាត់ឲ្យស៊ើបសួរជំនួស ដីកាកោះ ផែនទី រូបថត)។

ឃ) **Research and Authorities** (**ការស្រាវជ្រាវ និងប្រភពឯកសារយោង**) (អត្ថបទរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ សៀវភៅ របាយការណ៍វិភាគ អត្ថបទសារព័ត៌មាន (ផ្នែក ២) បញ្ជីឯកសារ)។

ង) **Statements and testimonial evidence** (**សេចក្តីថ្លែងការ និងភ័ស្តុតាងជាសក្ខីកម្ម**) (សេចក្តីថ្លែងការរបស់ជនសង្ស័យ ប្រតិចារឹក ពាក្យសុំរបស់ជនរងគ្រោះ ឯកសាររបស់ជនរងគ្រោះ កំណត់ហេតុស្តាប់ចម្លើយសាក្សី Proces Verbal)។

30. ដើម្បីលើកកម្ពស់ការអនុវត្តស៊ីចង្វាក់គ្នានៅទូទាំងសំណុំរឿងទាំងអស់ ការវិភាគនៅក្នុងផ្នែក V រៀបរាប់សង្ខេបបញ្ហាពាក់ព័ន្ធនៅក្នុងប្រភេទនីមួយៗ អនុសាសន៍របស់ ស.ព.អ ទាក់ទងនឹងបញ្ហាទាំងនោះនិងសំអាងហេតុគាំទ្រអនុសាសន៍របស់ខ្លួន។ ស.ព.អ ក៏បានរៀបចំឧបសម្ពន្ធរៀបរាប់ពិស្តារអំពីអនុសាសន៍ជាក់លាក់របស់ខ្លួនសម្រាប់សំណុំរឿង ០០៤/២ ផងដែរ ដើម្បីផ្តល់នូវឧទាហរណ៍ច្បាស់លាស់ ដែលនឹងជួយដល់អង្គជំនុំជម្រះក្នុងការធ្វើការសម្រេចលើការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញរបស់ខ្លួន ឲ្យបានកាន់តែទូលំទូលាយសម្រាប់រឿងក្តីទាំងអស់[43]។ ខណៈដែលការវិភាគណែនាំឲ្យមានការរក្សាការសម្ងាត់ ស.ព.អ ជំរុញឲ្យអង្គជំនុំជម្រះបង្ហាញឲ្យបានច្បាស់នៅក្នុងគោលការណ៍ចូលមើលរបស់ខ្លួន ថាតើឯកសារអ្វីអាចអនុញ្ញាតសម្រាប់ការចូលមើលមានកំណត់ លក្ខណៈវិនិច្ឆ័យអ្វីខ្លះត្រូវបំពេញដើម្បីទទួលបានការអនុញ្ញាតចូលមើលនោះ និងថាតើលក្ខខណ្ឌនៃការប្រើប្រាស់អ្វីខ្លះត្រូវកំណត់លើការចូលមើលនោះ ដើម្បីបន្តការការពារព័ត៌មានរសើបដែលមានក្នុងឯកសារទាំងនោះ[44]។

31. ជាចុងក្រោយ ឯកសាជាច្រើនក្នុងចំណោមឯកសារដែលបានធ្វើចំណាត់ថ្នាក់ថ្មីៗជាឯកសារសម្ងាត់ក្នុងសំណុំរឿង ០០៤/២ នេះ អាចរកបានជាសាធារណៈនៅកន្លែងផ្សេងទៀតរួចទៅហើយនៅក្នុង

---

[43] ឧបសម្ពន្ធសម្ងាត់ចំនួន ២៦ ដែលរៀបរាប់លម្អិតអំពីឯកសារជាក់លាក់ដែលស្នើសុំឲ្យធ្វើចំណាត់ប្រភេទឡើងវិញ ក្នុងសំណុំរឿង ០០៤/២។ ដើម្បីកាត់បន្ថយការយល់ច្រឡំអំពីថាតើ ឯកសារមួយណាត្រូវបានស្នើសុំធ្វើចំណាត់ប្រភេទឡើងវិញនោះ ឧបសម្ពន្ធទាំងនេះរក្សាទុកនូវការកំណត់ប្រភេទឯកសារដែលបានកំណត់ក្នុង Zylab ក៏ដូចជាកំហុសក្នុងការប្រកបណាមួយ ដែលអាចមាននៅក្នុងប្រអប់ "ចំណងជើងឯកសារ"។

[44] *សូមមើល* កថាខណ្ឌ ៧ *យោងខាងលើ* និងគោលការចូលមើល ដែលបានយោងខាងក្នុងនោះជាឧទាហរណ៍។

សំណុំរឿង អ.វ.ត.ក ផ្សេងទៀតឬតាមរយៈប្រភពនានាតាមអ៊ីនធើណិត។ នៅពេលដែលជាឯកសារសាធារណៈរួចទៅហើយនៅក្នុងសំណុំរឿងផ្សេង លេខឯកសារដែលពាក់ព័ន្ធត្រូវបានកត់សម្គាល់នៅក្នុងឧបសម្ព័ន្ធ។ ចំណុចនេះមិនមែនមានន័យថាឯកសារដែលទៅជាសាធារណៈហើយនោះ គួរតែធ្វើវាឱ្យទៅជាសាធារណៈក្នុងសំណុំរឿង ០០៤/២ នោះទេ នៅពេលដែលឯកសារបែបនោះលើកឡើងអំពីក្តីកង្វល់ទាក់ទងនឹងសន្តិសុខ និងភាពឯកជន។ ចំណុចនេះកត់សម្គាល់តែសម្រាប់ការជួយក្នុងតាមដានឯកសារទាំងនោះ ដើម្បីធ្វើឱ្យសេចក្តីសម្រេចធ្វើចំណាត់ប្រភេទ និង/ឬ ធ្វើការកោសលុបរបស់អង្គជំនុំជម្រះ អាចអនុវត្តប្រកបដោយសង្គតភាពក្នុងរឿងក្តីទាំងអស់[45]។

## V. ការវិភាគការលើការធ្វើចំណាត់ប្រភេទ

### ក. ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ

32. ឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យ មានប្រភេទឯកសារចំនួន ១០ សំខាន់ៗ៖ (១) សេចក្តីថ្លែងការណ៍ជាសាធារណៈ (២) កំណត់ហេតុកិច្ចប្រជុំ (៣) របាយការណ៍ (៤) ទូរលេខ (៥) បញ្ជីអ្នកទោស (៦) ប្រវត្តិរូប (៧) ចម្លើយសារភាព (៨) សៀវភៅកត់ត្រា (៩) អត្ថបទសារព័ត៌មាន និង (១០) វិធាន និងបទបញ្ជា។

33. ឯកសារទាំងអស់នេះ ត្រូវបានបង្កើតឡើងភ្លាមៗមុនពេល ឬក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ ជារួម ពួកវាជួយបង្ហាញពីគោលនយោបាយជាតិ និង ធាតុផ្សំដែលកំណត់យុត្តាធិការចាំបាច់សម្រាប់បញ្ជាក់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ពួកវាក៏ផ្តល់នូវភស្តុតាងអំពីឋានានុក្រមរដ្ឋបាល និងរចនាសម្ព័ន្ធរាយការណ៍របស់របបកម្ពុជាប្រជាធិបតេយ្យផងដែរ ដែលមានសារសំខាន់ក្នុងការអនុវត្តគោលនយោបាយ ប.ក.ក និងប្រភពនៃសហឧក្រិដ្ឋកម្មរួម។ ជាលទ្ធផលពួកវាសំខាន់សម្រាប់គោលបំណងភស្តុតាង និងប្រវត្តិសាស្ត្រ។

34. អាស្រ័យលើការលើកលែងមួយចំនួនដែលបានកត់សម្គាល់ខាងក្រោម ស.ព.អ ផ្តល់ជាអនុសាសន៍ថាឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យគួរតែធ្វើឱ្យទៅជាសាធារណៈ ដើម្បីបម្រើដល់គោលការណ៍តម្លាភាព។ រយៈពេលកន្លងទៅជាង ៤០ ឆ្នាំមកហើយ ចាប់តាំងពីឯកសារទាំងនោះបានបង្កើតឡើង ហើយពួកវាជាទូទៅមិនមានព័ត៌មានដែលអាចរំលោភបំពានដល់សិទ្ធិជាឯកជនរបស់

[45] ស.ព.អ ចាត់ទុកព័ត៌មានផ្ទាល់ខ្លួនថា ចាំបាច់ត្រូវការពារ ហើយហេតុដូច្នេះ ត្រូវកោសលុប រួមមាន តែមិនកំណត់ត្រឹមព័ត៌មានដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ រូបថតបង្ហាញមុខសាក្សី ព័ត៌មានលម្អិតទាក់ទងនឹងទីកន្លែងស្នាក់នៅរបស់ពួកគេ (រួមមានឈ្មោះភូមិ) លេខទូរសព្ទ ឈ្មោះសមាជិកគ្រួសារ និងព័ត៌មានទាក់ទងនឹងសុខភាពផ្លូវចិត្ត និងរាងកាយ។

បុគ្គលណាមួយដែលបានរៀបរាប់នោះឡើយ។ ការធានាឲ្យមានការចូលមើលជាសាធារណៈនូវឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យនេះ និងអនុញ្ញាតឲ្យមនុស្សជំនាន់ក្រោយ និងអ្នកស្រាវជ្រាវយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍ និងបទចោទនានាក្នុងរឿងក្តី។

35. ឯកសារជាច្រើនក្នុងចំណោមឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យ មានជាសាធារណៈរួចហើយនៅក្នុងសំណុំរឿង អ.វ.ត.ក ផ្សេងទៀត ឬ តាមរយៈប្រភពតាមអ៊ីនធើណិត ហើយលើកលែងតែកត់សម្គាល់ផ្សេងពីនេះ ឯកសារណាដែលមិនទាន់មានជាសាធារណៈ មិនមានព័ត៌មានដែលចាំបាច់ត្រូវបន្តការសម្ងាត់ទៀតឡើយ។

## ១. *សេចក្តីថ្លែងការណ៍ជាសាធារណៈ*

36. ឯកសារទាំងអស់នេះជាចំបងជាសេចក្តីថ្លែងការណ៍ជាសាធារណៈ និងការទំនាក់ទំនង ដែលធ្វើឡើងដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលរបបនោះ ដែលមិនចាំបាច់ត្រូវបន្តភាពសម្ងាត់ទៀតទេ និងអាចរកបាននៅក្នុងវិស័យសាធារណៈរួចទៅហើយ។ ចំពោះសំណុំរឿង ០០៤/២ ស.ព.អ ស្នើឡើងថា ឯកសារចំនួន ២៥ ក្នុងចំណោមឯកសារ ២៧ នៅក្នុងប្រភេទកំណត់ត្រានេះ ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញ ដូចបានបង្ហាញនៅក្នុងឧបសម្ពន្ធ ក-១[46]។ ដូចបានកត់សម្គាល់នៅក្នុងឧបសម្ពន្ធ ឯកសារដែលស្នើឡើងទាំងអស់មានជាសាធារណៈនៅក្នុងសំណុំរឿង ០០១ សំណុំរឿង ០០២ ឬទាំងពីរសំណុំរឿង។

## ២. *កំណត់ហេតុអង្គប្រជុំ*

37. ឯកសារនៅក្នុងប្រភេទកំណត់ត្រានេះ រួមមានកំណត់ហេតុពីការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក (ហៅម្យ៉ាងទៀតថា "គណៈអចិន្ត្រៃយ៍" ក្នុង Zylab) កិច្ចប្រជុំក្រសួង និងការប្រជុំតាមប្រធានបទ (ការប្រជុំរបស់ក្រសួង ក្រសួងពាណិជ្ជកម្ម ការប្រជុំទាក់ទងនឹងកិច្ចការសាធារណៈ បញ្ហាក្នុងប្រទេស សង្គមកិច្ច និងសុខាភិបាល) ការប្រជុំថ្នាក់ដឹកនាំយោធា (កងពល និងកងវរសេនាធំ) ការប្រជុំនៃ "សភាតំណាងប្រជាជនកម្ពុជា" និងកិច្ចចរចារពាណិជ្ជកម្មរវាងគណៈប្រតិភូមិកម្ពុជាប្រជាធិបតេយ្យនិងប្រទេសចិន។ ឯកសារមកពីកិច្ចប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិ ដែល

[46] ឯកសារដែលនៅសល់ចំនួនពីរ នៅក្នុងប្រភេទកំណត់ត្រានេះ មិនត្រូវបានស្នើសុំឲ្យធ្វើចំណាត់ប្រភេទឡើយ ដោយហេតុថាពួកវាត្រូវបានដាក់ភ្ជាប់ជាឯកសារសំអាងផ្លូវច្បាប់ទៅនឹងសារណារបស់ភាគី និងជាសេចក្តីថ្លែងការណ៍ជាសាធារណៈធ្វើឡើងដោយ ស.ព.អ មិនមែនដោយអតីតមន្ត្រី ប.ក.ក នោះទេ។

ក្នុងនោះ អៀង សារី ធ្វើសេចក្តីថ្លែងក្នុងនាមតំណាងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ក៏មានបញ្ចូលផងដែរ។មិនមានបញ្ហាណាក្នុងចំណោមបញ្ហាទាំងអស់នេះតម្រូវឱ្យមានការបន្តការការពារទៀតទេ។

38. ចំពោះសំណុំរឿង ០០៤/២ ស.ព.អ ស្នើសុំឱ្យធ្វើឱ្យទៅជាសាធារណៈទាំងអស់នូវឯកសារចំនួន ១៦៥ (កំណត់ហេតុការប្រជុំ") ដូចបានរៀបរាប់លម្អិតក្នុងឧបសម្ពន្ធ ក-២[47]។

## ៣. *របាយការណ៍*

39. ឯកសារក្នុងប្រភេទកំណត់ហេតុនេះ រួមមានសេចក្តីរាយការណ៍សម័យកម្ពុជាប្រជាធិបតេយ្យ ពីមន្ត្រី បកក របាយការណ៍ស៊ើបអង្កេតតាមតំបន់របស់ DC-Cam របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ពីការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") កំណត់ហេតុនៃកិច្ចស៊ើបសួរដែលលម្អិតអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការស៊ើបសួរទាក់ទងទៅនឹងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីសក្តានុពល របាយការណ៍ដែលសង្ខេបនូវខ្លឹមសារពីទម្រង់បែបបទព័ត៌មានជនរងគ្រោះ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងរបាយការណ៍ដែលភ្ជាប់ជាប្រភពឯកសារយោង ឬឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងសារណា។

40. ដោយសាររបាយការណ៍ដែលមានក្នុងប្រភេទកំណត់ហេតុនេះមានគោលបំណងខុសៗគ្នា និងបើតាមព័ត៌មានរសើប ឬព័ត៌មានផ្ទាល់ខ្លួនដែលមានក្នុងរបាយការណ៍ទាំងនេះ ស.ព.អ សូមផ្តល់អនុសាសន៍ជាក់លាក់ដូចតទៅ។ ចំពោះឯកសារសហកាលិកផ្សេងទៀត ស.ព.អ សូមផ្តល់អនុសាសន៍ឱ្យដាក់របាការណ៍សម័យកម្ពុជាប្រជាធិបតេយ្យជាសាធារណៈ ដោយមូលហេតុដូចបានជម្រាបជូនពីមុន[48]។ របាយការណ៍ស៊ើបអង្កេតតាមតំបន់របស់ DC-Cam ដែលពាក់ព័ន្ធនឹងសំណុំរឿង ក៏អាចដាក់ជាសាធារណៈដោយសុវត្ថិភាពបានដែរ[49]។ ដើម្បីលើកកម្ពស់តម្លាភាពនិងការអប់រំ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងគួរតែធ្វើចំណាត់ថ្នាក់ឡើងវិញ ប៉ុន្តែដើម្បីធ្វើដូច្នេះបានទាល់តែមានការកំណត់

---

[47] វាមានសារសំខាន់ក្នុងការកត់សម្គាល់ថា ឯកសារ **D219/487.1.3** មានសំណៅកោសលុបជាធាធារណៈនៅក្នុងសំណុំរឿង ០០១ (**E3/412**)។ ប្រសិនបើធ្វើទៅជាសាធារណៈក្នុងសំណុំរឿង ០០៤/២ ស.ព.អ ផ្តល់ជាយោបល់ថា សំណៅកោសលុបក្នុងសំណុំរឿង ០០១ ត្រូវរក្សាទុកក្នុងសំណុំរឿង ០០៤/២ ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកផ្តល់សម្ភាសន៍ និងដើម្បីធ្វើឱ្យមានសង្គតភាពនៅទូទាំងសំណុំរឿងទាំងអស់។

[48] *សូមមើល* កថាខណ្ឌ ៣៣-៣៥ ខាងលើ។

[49] ស.ព.អ កត់សំគាល់ថា របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង និងរបាយការណ៍ស៊ើបអង្កេត DC-Cam អាចមាននៅក្នុងសំណុំរឿង ប៉ុន្តែមិនពាក់ព័ន្ធទៅនឹងករណីជាក់លាក់នោះដោយសារលក្ខណៈរួមនៃសំណុំរឿងមួយមុនបំបែកកិច្ចដំណើរការនីតិវិធី (ដូចនៅក្នុងសំណុំរឿង ០០៤/២ ដែរ)។

ថាតើត្រូវមានការកោសលុបព័ត៌មានចាំបាច់ជាមុនសិនដែរឬទេ ដើម្បីការពារអត្តសញ្ញាណរបស់ប្រភពដែលផ្តល់តម្រុយក្នុងកិច្ចស៊ើបសួរ និងដែលមិនឯកភាពផ្តល់កំណត់ហេតុជាផ្លូវការណ៍[50]។ ស្រដៀងគ្នានេះ របាយការណ៍ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលគិតថាអាចទទួយកបានដោយ ស.ច.ស (ឬ ស.ច.ស.អ) គួរតែធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ ប៉ុន្តែទាល់តែព័ត៌មានទំនាក់ទំនង និងព័ត៌មានឯកជន ឬព័ត៌មានរសើបត្រូវបានកោសលុបជាមុនសិន[51]។

41. ផ្ទុយទៅវិញ របាយការណ៍ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះដែល *មិន*ត្រូវបានទទួលយកនៅក្នុងសំណុំរឿង *មិន*គួរធ្វើទៅជាសាធារណៈឡើយ[52]។ ស.ព.អ ក៏សូមផ្តល់អនុសាសន៍ផងដែរថា អាស្រ័យលើករណីលើកលែងមានកំហិតតិចតួច កំណត់ហេតុនៃកិច្ចស៊ើបសួរនៅរក្សាទុកជាសម្ងាត់ ដោយសារកំណត់ហេតុប្រភេទនេះតែងមានព័ត៌មានរសើបឬព័ត៌មានផ្ទាល់ខ្លួនដែលទាមទារឲ្យមានការការពារជាបន្ត[53]។

42. ជាចុងក្រោយ ស.ព.អ យល់ឃើញថា ឯកសារដែលបានភ្ជាប់ជាប្រភពឯកសារយោង ឬឧបសម្ព័ន្ធទៅនឹងសារណា គួររក្សាជាការសម្ងាត់ដដែល។ ដូចបានពិភាក្សានៅទូទាំងសំណើនេះ ឯកសារដូច្នេះអាចរកបានជាសាធារណៈនៅកន្លែងផ្សេងឬមានការការពារដោយសិទ្ធិចម្លង(កម្មសិទ្ធិបញ្ញា) ឬវិធានការសម្ងាត់ផ្សេងទៀត។ ការធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះតារាងឯកសារយោង (TOAs) ដោយរក្សាប្រភពឯកសារយោងជាមូលដ្ឋាននៅជាសម្ងាត់ (ក្នុងករណីនេះ គឺរបាយការណ៍) នឹងបញ្ចៀស អ.វ.ត.ក ពីការរំលោភកិច្ចការពារដូច្នេះ និងដាក់*បន្ទុក*លើអ្នកប្រើប្រាស់ក្នុងការស្វែងរកការអនុញ្ញាតឲ្យបានត្រឹមត្រូវ ដើម្បីមានសិទ្ធិចូលមើល និង/ឬ ប្រើប្រាស់សម្ភារទាំងនោះ។

43. ក្នុងសំណុំរឿង០០៤/២ ស.ព.អ ស្នើសុំការធ្វើចំណាត់ថ្នាក់ឡើងវិញលើរបាយការណ៍ជាង ៥៨៥ ក្នុងចំណោមរបាយការណ៍សម្ងាត់ និងសម្ងាត់បំផុតចំនួន ៥.៣៤០ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ក-

---

[50] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ២៣-២៤ ខាងលើ។

[51] *សូមមើល* កថាខណ្ឌ ២២-២៤ ខាងលើ។ *សូមមើលផងដែរ* ជើងទំព័រលេខ ៣២ (យោង ភាពអាចទទួលយកបានដែលបានកំណត់ដោយ ស.ច.ស តែម្នាក់), ៤៥ (ផ្តល់ឧទាហរណ៍ខ្លះអំពីប្រភេទព័ត៌មានដែលគួរប្បីកោសលុប)) ខាងលើ។

[52] *សូមមើលជាពិសេស* កថាខណ្ឌ ២២ ខាងលើ។

[53] *សូមមើល* កថាខណ្ឌ ២២-២៤ ខាងលើ។ ឯកសារទាំងនេះជាញឹកញាប់កំណត់អត្តសញ្ញាបុគ្គលដែលមិនយល់ព្រមផ្តល់ការកិច្ចសម្ភាសន៍ជាផ្លូវការណ៍ ប៉ុន្តែបាននិយាយជាមួយយើងដោយចំហ ដោយមានការរំពឹងថា តួនាទីរបស់ពួកគេក្នុងការផ្តល់តម្រុយក្នុងកិច្ចស៊ើបសួរនៅតែរក្សាបាននូវការសម្ងាត់។

៣[54]។ កំណត់ហេតុទាំងនេះរួមបញ្ចូលទាំង សេចក្តីរាយការណ៍សម័យកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើឡើងដោយមន្ត្រី បកក និងរបាយការណ៍ស៊ើបអង្កេតរបស់ DC-Cam ទាក់ទងនឹងតំបន់នានាក្នុងសំណុំរឿង ០០៤/២។ ស.ព.អ ក៏សូមស្នើធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះរបាយការណ៍កំណត់អត្តសញ្ញាណទីតាំងរបស់ ក.ស.ច.ស ដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលបានកិច្ចស៊ើបសួរលើ អោ អាន ផងដែរ[55] ប៉ុន្តែ *មិនមែន* របាយការណ៍កំណត់អត្តសញ្ញាណទីតាំង ដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរលើ អ៊ឹម ចែម និង យឹម ទិត្យ ដែលមានលក្ខណៈសមស្របដើម្បីធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងករណីនីមួយៗនោះទេ[56]។ ដើម្បីឲ្យស្របនឹងគោលការណ៍ដូចបានថ្លែងខាងលើ ស.ព.អ *មិន*

[54] "របាយការណ៍" សម្ងាត់បន្ថែមត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធសម្ភារដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ (ឧបសម្ព័ន្ធ ង-៤) ដាក់ជាក្រុមតាមលំដាប់លំដោយដែលមានឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ។

[55] ឯកសារ **D219/584** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តតាមាយ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥។ ឯកសារ **D3/21** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង គ (មិត្តសុប) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០។ ឯកសារ **D3/23** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ភ្នំប្រុស ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០។ ឯកសារ **D117/48** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តអង្គញ្ជី និងទួលបេង ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤។ ឯកសារ **D107/16** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង គោកព្រីង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D3/25** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តបាធាយ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១។ ឯកសារ **D3/24** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ទំបន់អន្លង់ជ្រៃ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១១។ ឯកសារ **D6.1.397** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អូត្រកួន ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩។ ឯកសារ **D107/17** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការស្វាយចន្ទី ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១២។ ឯកសារ **D6.1.391** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តបារាយណ៍ជាន់ដែក ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៩។ ឯកសារ **D117/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តស្រង៉ែ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២។ ឯកសារ **D117/16** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តកណ្តាល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២។ ឯកសារ **D117/36.1.30** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ភូមិទ្រា ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩។

[56] សម្រាប់គោលបំណងនៃកិច្ចខិតខំប្រឹងប្រែងធ្វើចំណាត់ថ្នាក់ឡើងវិញនាពេលអនាគតនៅក្នុងសំណុំរឿងពីរផ្សេងទៀត របាយការណ៍ពាក់ព័ន្ធសម្រាប់សំណុំរឿង ០០៤/១ (អ៊ឹម ចែម) និង ០០៤ (យឹម ទិត្យ) គឺមានដូចតទៅ៖ **អ៊ឹម ចែម:** ឯកសារ **D106/12** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តព្រះនេត្រព្រះ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ភូមិចក្រី និងព្រៃតារត់ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D106/18** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ភ្នំទ្រយោង ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២។ ឯកសារ **D106/19** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្ពានស្រែង និងទំបន់ព្រៃនាម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២។ ឯកសារ **D118/38** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តចម្ការកុល ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣។ ឯកសារ **D119/9** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តអង្គសិរីមាលី ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២។ ឯកសារ **D119/10** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ព្រៃសុខុន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២។ ឯកសារ **D119/46** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ផ្ទះតាក្រក ចម្ការដូង និងចម្ការយាយណឹង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៣។ ឯកសារ **D6.1.710** របាយ

ការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ទនប់អាងត្រពាំងថ្ម ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១០។ **<u>យីម ទិត្យៈ</u>** ឯកសារ **D3/22** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តប្រធាតុ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០។ ឯកសារ **D6.1.149** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ក្រាំងតាចាន់ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨។ ឯកសារ **D6.1.150** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តគិរីរម្យ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨។ ឯកសារ **D6.1.395** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តសំរោងក្នុង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨។ ឯកសារ **D105/10** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តកណ្តាល ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D105/11** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តសម្តេច ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D105/12** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តពោធិលង្កា ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D105/13** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តធម្មយុត្តិ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D105/14** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង បន្ទាយត្រែង ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១២។ ឯកសារ **D105/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង បន្ទាយអូតាគ្រែ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១២។ ឯកសារ **D105/16** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តធិបតី ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ ឯកសារ **D105/17** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តសុបិន ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ ឯកសារ **D105/18** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ទួលម្ទេស ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ ឯកសារ **D105/19** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខតំបន់ ១ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ ឯកសារ **D105/20** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង គុកលេខ៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ ឯកសារ **D118/11** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ភូមិវាល ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣។ ឯកសារ **D118/12** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ទួលសេះញ៉ូវ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣។ ឯកសារ **D118/13** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ព្រៃក្របៅ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣។ ឯកសារ **D118/14** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តចន្ទរង្សី ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣។ ឯកសារ **D118/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្វាយជ្រុំ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣។ ឯកសារ **D118/16** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ត្រាចក្រោល ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។ ឯកសារ **D118/32** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ភ្នំត្រដាក់ចិត្ត ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣។ ឯកសារ **D118/35** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អន្លង់វិលប្រែង និងឆ្នាល់មាន់ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣។ ឯកសារ **D118/36** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តបន្ទាយនាង ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៣។ ឯកសារ **D118/37** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង គាស់ក្រឡ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៣។ ឯកសារ **D118/146** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខបាណន (តំបន់ ១) ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៣។ ឯកសារ **D119/9** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តអង្គស្រីមាលី ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២។ ឯកសារ **D119/10** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ព្រៃសុខុន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២។ ឯកសារ **D134/6** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វាលបាក់ចិញ្ចៀន ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។ ឯកសារ **D219/271** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខធិបតី ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥។ ឯកសារ **D219/272** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ទំនប់កង្កួត ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥។ ឯកសារ **D219/273** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ខ្ទងគូ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥។ ឯកសារ **D219/274** របាយការណ៍ស្តីពី

ស្នើសុំធ្វើចំណាត់ថ្នាក់ឡើងវិញលើរបាយការណ៍ដែលបានភ្ជាប់ជាប្រភពឯកសារយោង ឬឧបសម្ព័ន្ធភ្ជាប់ទៅនឹងសារណានិងរបាយការណ៍ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលគិតថា មិនអាចទទួលយកបានដោយ ស.ច.ស.អ[57]នោះទេ។ របាយការណ៍សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលអាចទទួលយកបាន និងពាក្យបណ្តឹង ត្រូវបានស្នើឲ្យធ្វើចំណាត់ប្រភេទឡើងវិញ អមជាមួយសម្ភារជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងឧបសម្ព័ន្ធ ង-៤ ដូចបានពិភាក្សាខាងក្រោម។

## ៤. *ទូរលេខ*

44. ឯកសារក្នុងប្រភេទកំណត់ហេតុនេះ ជាចំបងគឺជាទូរលេខសម័យកម្ពុជាប្រជាធិបតេយ្យដែលផ្តល់ជាអាទិ៍ដូចជា ភ័ស្តុតាងអំពីរចនាសម្ព័ន្ធនៃការប្រាស្រ័យទំនាក់ទំនង និងសេចក្តីរាយការណ៍របស់ឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ការចេញសារាចរណ៍ណែនាំនិងការអនុវត្តសារាចរណ៍ណែនាំទាំងនោះ។ តម្រូវការក្នុងការរក្សាការសម្ងាត់ចំពោះព័ត៌មានដូច្នេះ លែងចាំបាច់ទៀតហើយ។ នៅក្នុងសំណុំរឿង ០០៤/២ ស.ព.អ សូមស្នើការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារសម្ងាត់ចំនួន ៥៧៨ ក្នុងចំណោមឯកសារ ៥៨៣ ក្នុងប្រភេទកំណត់ហេតុនេះ ដូចបានរៀបរាប់លម្អិតក្នុងឧបសម្ព័ន្ធ ក-៤[58]។

## ៥. *បញ្ជីអ្នកទោស*

45. ឯកសារទាំងនេះរួមបញ្ចូលទាំងបញ្ជីអ្នកទោសដែលត្រូវបានសួរចម្លើយ និង/ឬ សម្លាប់នៅតាមបណ្តាមន្ទីរសន្តិសុខនានារបស់កម្ពុជាប្រជាធិបតេយ្យ និងរបាយការណ៍រដ្ឋបាលផ្សេងទៀត ទាក់ទងនឹងអ្នកទោស។ ជារួម ឯកសារទាំងនេះបង្ហាញអំពីក្រុមគោលដៅជាក់លាក់ដែលគេបានកំណត់ និងជួយក្នុងការកំណត់អំពីលក្ខណៈនៃការវាយប្រហារដ៏រាលដាល។ វាត្រូវបានរៀបចំឡើងក្នុងដំណើរធម្មតាមួយក្នុងការគ្រប់គ្រងក្បាលម៉ាស៊ីនសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ដូច្នេះឯកសារទាំងនេះមិនមែនជាផលិតផលនៃការធ្វើទារុណកម្មទេ យើងអាចធ្វើឲ្យវាទៅជាសាធារណៈដោយសុវត្ថិភាព។

---

ការកំណត់អត្តសញ្ញាណទីកន្លែង រោងចក្រស្ករសកំពង់កុល ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥។ ឯកសារ **D219/500** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឃុំវាំងកេសី ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥។

[57] ស.ព.អ សង្កេតឃើញថា មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះជាច្រើន ត្រូវបានយល់ថា មិនអាចទទួលយកបានក្នុងសំណុំរឿង ០០៤/២ ដោយសារវាពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរលើ អ៊ឹម ចែម ឬ យឹម ទិត្យ មិនមែនក្នុងករណី អោ អាន ប៉ុន្តែឯកសារទាំងនេះត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងមុនបំបែកកិច្ចដំណើរការនីតិវិធី។

[58] ឯកសារដែលនៅសល់ក្នុងជំពូកនេះ មិនស្នើឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញទេដោយសារវាជាសន្លឹកបន្ថែមដែលគ្រាន់តែយោងទៅរកលេខឯកសារដែលបានដាក់នាពេលក្រោយមក ដែលអាចឲ្យយើងរកបាននូវខ្លឹមសារដើមតែប៉ុណ្ណោះ។

46. សម្រាប់សំណុំរឿង ០០៤/២ ស.ព.អ សូមស្នើការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៣១៤ ក្នុងចំណោមឯកសារ ៣២៣ នៃឯកសារសម្ងាត់ក្នុងប្រភេទកំណត់ហេតុនេះ រួមបញ្ចូលទាំងបញ្ជីកម្មាភិបាលដែលត្រូវបានគេបោសសម្អាតពីភូមិភាគកណ្ដាលផង។ ឯកសារទាំងនេះមានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ក-៥។ មានឯកសារតែពីរបីប៉ុណ្ណោះដែល *មិន* ស្នើសុំឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញ ដោយសារវាមានព័ត៌មានរសើបដែលទាមទារឱ្យមានការការពារជាបន្ត[59]។

## ៦. ***ប្រវត្តិរូប***

47. កំណត់ហេតុទាំងនេះរួមមាន អត្តសញ្ញាណប័ណ្ណ និងសំបុត្រកំណើត/សំបុត្រមរណភាព របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីអនាគត អាជីវប្រវត្តិរបស់អ្នកជំនាញសក្ខីកម្ម ពលដែលមិនធ្លាប់ទាក់ទងកន្លងមកដើម្បីរាវស់ស្ទង់ផលប្រយោជន៍របស់ពួកគេក្នុងការធ្វើជាអ្នកជំនាញ ដោយសារសំណុំរឿងមិនបានដំណើរការទៅជំនុំជម្រះ និងប្រវត្តិរូបដែលប្រមូលបាន និងប្រើប្រាស់ដោយរបបកម្ពុជាប្រជាធិបតេយ្យដើម្បីកំណត់អត្តសញ្ញាណ និងគោលដៅខ្មាំង (ដែលបានផលិតឡើងក្រោមការបង្ខិតបង្ខំ ឬក្នុងករណីប្រវត្តិរូបរបស់មន្ទីរសន្តិសុខ ត្រូវបានសន្មតថា ដោយទារុណកម្ម)។

48. ដោយមានការលើកលែងខ្លះដូចខាងក្រោម ស.ព.អ សូមផ្ដល់អនុសាសន៍ឱ្យរក្សាទុកការធ្វើចំណាត់ថ្នាក់ក្នុងប្រភេទកំណត់ហេតុ"ប្រវត្តិរូប" នៅជាសម្ងាត់ដដែល ដោយសារផលប្រយោជន៍នៃតម្លាភាពមានទម្ងន់ស្រាលជាងយ៉ាងខ្លាំងធៀបនឹងតម្រូវការនៃការការពារអត្តសញ្ញាណ និង/ឬ ព័ត៌មានផ្ទាល់ខ្លួននិងព័ត៌មានរសើប ដែលជាសមាសភាគដ៏សំខាន់នៃខ្លឹមសាររបស់ឯកសារទាំងនេះ។

49. ស.ព.អ កត់សម្គាល់ថា ប្រវត្តិរូបអ្នកទោសមួយចំនួនត្រូវបានធ្វើឱ្យទៅជាសាធារណៈរួចហើយ នៅក្នុងសំណុំរឿង ០០១ និង/ឬ សំណុំរឿង ០០២ មកទល់ពេលនេះដើម្បីប្រយោជន៍សង្គតិភាព អង្គជំនុំជម្រះគួរពិចារណាកែប្រែការធ្វើចំណាត់ប្រភេទនេះ ឬធ្វើការកោសលុបទិន្នន័យបញ្ជាក់អត្តសញ្ញាណនៅក្នុងសំណុំរឿងទាំងអស់ ដែលមានឯកសារទាំងអស់នេះ[60]។ ជាគោលការណ៍ ស.ព.អ ឯកភាព

---

[59] ឯកសារទាំងនេះរួមបញ្ចូលទាំង ចម្លើយសារភាពរបស់អ្នកទោស ស-២១ (**D6.1.87**, **D6.1.88**) ដែលត្រូវបានសន្មតថា បានផលិតឡើងក្រោមការធ្វើទារុណកម្ម និងមានបញ្ជីអ្នកទោសមួយដែលដាក់ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយត្រូវបាន ស.ច.ស.អ គិតថាមិនអាចទទួលយកបានសម្រាប់សំណុំរឿង ០០៤/២ (**D5/275.9**)។ ដូចបានកត់សំគាល់ក្នុងកថាខណ្ឌ ៤, ២២ និង ២៥ ខាងលើ ឯកសារដូច្នេះគួរតែរក្សាទុកជាការសម្ងាត់។

[60] *សូមមើល ឧទាហរណ៍* **<u>សំណុំរឿង ០០១</u>៖** ឯកសារ **E3/503/2** (D219/444.1.3 ក្នុងសំណុំរឿង ០០៤/២)។ **E3/222** (D219/702.1.55 ក្នុងសំណុំរឿង ០០៤/២ *មើលជាពិសេស* ទំព័រ ៣-៦ នៃឯកសារ)។ **<u>សំណុំរឿង ០០២</u>៖** ឯកសារ **E3/7508** (D132.1.11 ក្នុងសំណុំរឿង ០០៤/២); **E3/1533** (D219/702.1.44 ក្នុងសំណុំរឿង ០០៤/២); **E3/961** (D219/702.1.55

ជាមួយនឹងវិធីសាស្ត្រដែលបានប្រើដោយ TSGM ដូចបានពិភាក្សានៅក្នុងកថាខណ្ឌ ២៥ ខាងលើ និងសូមផ្តល់អនុសាសន៍ឲ្យ អ.ជ.ត.ក គួរអនុវត្តវិធីសាស្ត្រពិតប្បិតស្រដៀងគ្នានេះ ទាក់ទងនឹងការចូលមើលខ្លឹមសារឯកសារទាំងអស់នេះ[61]។

50. ទាក់ទងនឹងសំណុំរឿង ០០៤/២ ស.ព.អ ស្វែងរកឲ្យមានការធ្វើឲ្យទៅជាសាធារណៈតែឯកសារចំនួន ៨ ប៉ុណ្ណោះ ក្នុងចំណោមឯកសារសម្ងាត់ចំនួន ៣៨៣ នៅក្នុងប្រភេទកំណត់ត្រានេះ។ ឯកសារទាំងប្រាំបីនេះមិនស្ថិតនៅក្នុងដែនកំណត់ ដែលចាំបាច់ត្រូវបន្តការការពារនោះទេ ដោយសារតែពួកវាមានកាលបរិច្ឆេទនៅក្រោយសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងមិនមែនជាផលនៃការធ្វើទារុណកម្មឡើយ។ ពួកវារួមមានប្រវត្តិក្រោយរបបកម្ពុជាប្រជាធិបតេយ្យរបស់ កែវ ពក ដែលជាលេខាភូមិភាគកណ្តាល និងជាអ្នកគ្រប់គ្រងផ្ទាល់របស់ អោ អាន និងសេចក្តីថ្លែងដែលធ្វើឡើងក្នុងឆ្នាំ ២០០០ ដោយអតីតអ្នកក្រោមបង្គាប់ផ្ទាល់របស់ អៀង សារី ម្នាក់នៅក្រសួងការបរទេស។ សូមមើលឧបសម្ពន្ធ ក-៦ សម្រាប់ព័ត៌មានលម្អិត។

## ៧. *ចម្លើយសារភាព*

51. ឯកសារនៅក្នុងប្រភេទកំណត់ត្រានេះ ភាគច្រើនជាចម្លើយសារភាពអ្នកទោសមន្ទីរសន្តិសុខ ដែលតាមសន្មតបង្កើតឡើងក្រោមការធ្វើទារុណកម្ម ឬការគំរាមកំហែងនៃអំពើទារុណកម្ម។ ឯកសារមួយចំនួនមានចំណារដែលធ្វើឡើងដោយមន្ត្រី ប.ក.ក ដែលផ្តល់ការណែនាំទាក់ទងនឹងជោគវាសនារបស់អ្នកទោស។ រួមបញ្ចូលគ្នា ឯកសារទាំងនេះបង្កើតបានជាភ័ស្តុតាងអំពីការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់ជាប្រព័ន្ធ និងស៊ីចង្វាក់គ្នា នៃអ្នកទាំងឡាយណាដែលរបបកម្ពុជាប្រជាធិបតេយ្យចាត់ទុកថាជាខ្មាំង ប៉ុន្តែតម្លៃជាសាធារណៈរបស់ពួកវាត្រូវបានលុបលើដោយការបង្កគ្រោះថ្នាក់ជាសក្តានុពល ដែលអាចបណ្តាលមកពីការធ្វើឲ្យកំណត់ត្រាទាំងនោះទៅជាសាធារណៈ[62]។

52. ហេតុដូច្នេះ ស.ព.អ ផ្តល់អនុសាសន៍ថា ឯកសារស្ថិតក្នុងប្រភេទកំណត់ត្រានេះនៅបន្តជាសម្ងាត់ដរាបណាសច្ចាធារណ៍នៃការធ្វើទារុណកម្មមិនត្រូវបានបដិសេធដោយជោគជ័យទេ។ គាត់ក៏ជម្រុញ

---

ក្នុងសំណុំរឿង ០០៤/២, *មើលជាពិសេស* ទំព័រ ៣-៦ នៃឯកសារ); **E3/7525** (D219/879.1.16 ក្នុងសំណុំរឿង ០០៤/២); **E3/7516** (D219/883.1.18 ក្នុងសំណុំរឿង ០០៤/២); **E3/9297** (D219/883.1.20 ក្នុងសំណុំរឿង ០០៤/២); **E3/7509** (D6.1.1239 ក្នុងសំណុំរឿង ០០៤/២); **E3/7592** (D6.1.1256 ក្នុងសំណុំរឿង ០០៤/២)។ *សូមមើលផងដែរ* ជើងទំព័រ ៤៥ *ខាងលើ*។

[61] *សូមមើលផងដែរ* កថាខណ្ឌ ៤ *យោងខាងលើ*។

[62] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៤ *យោងខាងលើ*។

ឲ្យ អ.វ.ត.ក អនុម័តវិធីសាស្ត្រដូចគ្នា ដែល TSGM ប្រើ ទាក់ទងនឹងការចូលមើលចម្លើយសារភាពមន្ទីរសន្តិសុខ[63]។

53. ស.ព.អ កត់សម្គាល់បន្ថែមទៀតថា ចម្លើយសារភាពអ្នកទោសមួយចំនួន ដែលតាមការយល់ឃើញរបស់គាត់ ចាំបាច់ត្រូវស្ថិតក្នុងចំណាត់ប្រភេទសម្ងាត់ ត្រូវបានធ្វើឲ្យទៅជាសាធារណៈរួចហើយ នៅក្នុងសំណុំរឿង ០០១ និង/ឬ សំណុំរឿង ០០២។ ដើម្បីឲ្យមានសង្គតភាព អង្គជំនុំជម្រះគួរពិចារណាថាតើការធ្វើចំណាត់ប្រភេទបែបទាំងនោះ គួរត្រូវរក្សា ឬកែប្រែ ឬថាតើគួរអនុវត្តការកោសលុបនៅក្នុងគ្រប់សំណុំរឿងទាំងអស់ ដែលមានឯកសារទាំងអស់នេះ ឬយ៉ាងណា[64]។

[63] *សូមមើល* កថាខណ្ឌ ២៥ *យោងខាងលើ*។

[64] **<u>សំណុំរឿង ០០១៖</u>** ឯកសារ **E3/72** (D1.3.4.2 ក្នុងសំណុំរឿង ០០៤/២); **D32/IV-Annex 26** (D219/702.1.16 ក្នុងសំណុំរឿង ០០៤/២); **E5/2.21** (D219/702.1.53 ក្នុងសំណុំរឿង ០០៤/២); **E3/501** (D6.1.1005 ក្នុងសំណុំរឿង ០០៤/២); **D32/IV-Annex 63** (D6.1.1025 ក្នុងសំណុំរឿង ០០៤/២); **E3/369** (D6.1.1114 ក្នុងសំណុំរឿង ០០៤/២); **E3/80** (D6.1.1119 ក្នុងសំណុំរឿង ០០៤/២); **E3/62** (D6.1.1124 ក្នុងសំណុំរឿង ០០៤/២); **E3/500** (D6.1.1126 ក្នុងសំណុំរឿង ០០៤/២); **E3/132** (D6.1.534 ក្នុងសំណុំរឿង ០០៤/២); **E3/72** (D6.1.541 ក្នុងសំណុំរឿង ០០៤/២); **E3/125** (D6.1.544 ក្នុងសំណុំរឿង ០០៤/២); **E3/110** (D6.1.545 ក្នុងសំណុំរឿង ០០៤/២). **<u>សំណុំរឿង ០០២៖</u>** ឯកសារ **E3/3989** (D1.3.18.2 ក្នុងសំណុំរឿង ០០៤/២); **E3/2650** (D1.3.4.11 ក្នុងសំណុំរឿង ០០៤/២); **E3/2792, E3/2794** (D1.3.4.2 ក្នុងសំណុំរឿង ០០៤/២); **E3/7403, E3/9446** (D1.3.4.4 ក្នុងសំណុំរឿង ០០៤/២); **E3/3192** (D1.3.4.6 ក្នុងសំណុំរឿង ០០៤/២); **E3/4322** (D131/2.1.121 ក្នុងសំណុំរឿង ០០៤/២); **E3/4432** (D131/2.1.136 ក្នុងសំណុំរឿង ០០៤/២); **E3/4260** (D131/2.1.143 ក្នុងសំណុំរឿង ០០៤/២); **E3/7432** (D191.1.110 ក្នុងសំណុំរឿង ០០៤/២); **E3/3645** (D219/702.1.1 ក្នុងសំណុំរឿង ០០៤/២); **E3/1826** (D219/702.1.14 ក្នុងសំណុំរឿង ០០៤/២); **E3/1546** (D219/702.1.16 ក្នុងសំណុំរឿង ០០៤/២); **E3/1687** (D219/702.1.17 ក្នុងសំណុំរឿង ០០៤/២); **E3/1709** (D219/702.1.21 ក្នុងសំណុំរឿង ០០៤/២); **E3/7218** (D219/702.1.53 ក្នុងសំណុំរឿង ០០៤/២); **E3/3646** (D6.1.1003 ក្នុងសំណុំរឿង ០០៤/២); **E3/3647** (D6.1.1004 ក្នុងសំណុំរឿង ០០៤/២); **E3/3648** (D6.1.1005 ក្នុងសំណុំរឿង ០០៤/២); **E3/7408** (D6.1.1009 ក្នុងសំណុំរឿង ០០៤/២); **E3/3654** (D6.1.1010 ក្នុងសំណុំរឿង ០០៤/២); **E3/7409** (D6.1.1011 ក្នុងសំណុំរឿង ០០៤/២); **E3/1706** (D6.1.1013 ក្នុងសំណុំរឿង ០០៤/២); **E3/2129** (D6.1.1014 ក្នុងសំណុំរឿង ០០៤/២); **E3/3665** (D6.1.1019 ក្នុងសំណុំរឿង ០០៤/២); **E3/3667** (D6.1.1021 ក្នុងសំណុំរឿង ០០៤/២); **E3/1558, E3/2325** (D6.1.1025 ក្នុងសំណុំរឿង ០០៤/២); **E3/3682** (D6.1.1027 ក្នុងសំណុំរឿង ០០៤/២); **E3/3683** (D6.1.1028 ក្នុងសំណុំរឿង ០០៤/២); **E3/7421** (D6.1.1034 ក្នុងសំណុំរឿង ០០៤/២); **E3/7434** (D6.1.1042 ក្នុងសំណុំរឿង ០០៤/២); **E3/3849** (D6.1.1044 ក្នុងសំណុំរឿង ០០៤/២); **E3/3856** (D6.1.1045 ក្នុងសំណុំរឿង ០០៤/២); **E3/3857** (D6.1.1046 ក្នុងសំណុំរឿង ០០៤/២); **E3/1831** (D6.1.1107 ក្នុងសំណុំរឿង ០០៤/២); **E3/1832** (D6.1.1108 ក្នុងសំណុំរឿង ០០៤/២); **E3/2129** (D6.1.1110 ក្នុងសំណុំរឿង ០០៤/២); **E3/1839** (D6.1.1111 ក្នុងសំណុំរឿង ០០៤/២); **E3/1842** (D6.1.1112 ក្នុងសំណុំរឿង ០០៤/២); **E3/1705** (D6.1.1114 ក្នុងសំណុំរឿង ០០៤/២); **E3/1604** (D6.1.1115 ក្នុងសំណុំរឿង ០០៤/២); **E3/1876** (D6.1.1119

54. ទាក់ទងនឹងសំណុំរឿង ០០៤/២ ស.ព.អ ស្វែងរកឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញសម្រាប់ឯកសារសម្ងាត់ចំនួន ៧ ក្នុងចំណោមឯកសារ ៤៩០ នៅក្នុងប្រភេកំណត់ត្រានេះ ដែលឯកសារទាំងអស់នេះត្រូវបានកំណត់ប្រភេទខុស៖ មួយគឺជាសារណារបស់ ស.ព.អ (មានពីរភាសា) និងឯកសារផ្សេងទៀតជាបទសម្ភាសន៍ដែលផ្ដល់ឲ្យក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ[65]។ ព័ត៌មានលម្អិតមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក-៧។

## ៨. *សៀវភៅកត់ត្រា*

55. ឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យ នៅក្នុងប្រភេទកំណត់ត្រានេះ រួមមានការកត់ត្រារបស់អ្នកសួរចម្លើយនៅមន្ទីរសន្តិសុខពីវគ្គបណ្ដុះបណ្ដាលមនោគមវិជ្ជា សៀវភៅសរសេររៀបរាប់លម្អិតអំពីខ្លឹមសារចម្លើយសារភាពអ្នកទោស សេចក្ដីព្រាងលក្ខខន្តិកៈ ប.ក.ក ការវិភាគរបស់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីរចនាសម្ព័ន្ធគណៈកម្មាធិការមជ្ឈិម និងអចិន្ត្រៃយ៍របស់ ប.ក.ក និងឯកសារពាក់ព័ន្ធនឹង អៀង សារី ដែលរួមមានសំណៅចម្លងផ្ទាល់ខ្លួនរបស់គាត់អំពីកំណត់ហេតុនៃការប្រជុំគណៈកម្មាធិការមជ្ឈិម និងអចិន្ត្រៃយ៍។

56. ស្ថិតក្រោមករណីលើកលែងមួយដែលបានកត់សម្គាល់ខាងក្រោម ស.ព.អ ផ្ដល់អនុសាសន៍ថាកំណត់ត្រាដែលបានធ្វើចំណាត់ប្រភេទថាជា "សៀវភៅសរសេរ" ត្រូវធ្វើឲ្យជាសាធារណៈ ដោយហេតុថាពួកវាបង្កើតបានជាភ័ស្តុតាងសំខាន់ អំពីការបណ្ដុះបណ្ដាលរបស់របបកម្ពុជាប្រជា

ក្នុងសំណុំរឿង ០០៤/២); **E3/1886** (D6.1.1122 ក្នុងសំណុំរឿង ០០៤/២); **E3/1889** (D6.1.1123 ក្នុងសំណុំរឿង ០០៤/២); **E3/1892** (D6.1.1124 ក្នុងសំណុំរឿង ០០៤/២); **E3/1625** (D6.1.1125 ក្នុងសំណុំរឿង ០០៤/២); **E3/1895** (D6.1.1126 ក្នុងសំណុំរឿង ០០៤/២); **E3/2421** (D6.1.205 ក្នុងសំណុំរឿង ០០៤/២); **E3/2431** (D6.1.230 ក្នុងសំណុំរឿង ០០៤/២); **E3/8426** (D6.1.286 ក្នុងសំណុំរឿង ០០៤/២); **E3/2462** (D6.1.309 ក្នុងសំណុំរឿង ០០៤/២); **E3/7353** (D6.1.311 ក្នុងសំណុំរឿង ០០៤/២); **E3/2464** (D6.1.314 ក្នុងសំណុំរឿង ០០៤/២); **E3/2474** (D6.1.326 ក្នុងសំណុំរឿង ០០៤/២); **E3/7366** (D6.1.329 ក្នុងសំណុំរឿង ០០៤/២); **E3/7372** (D6.1.335 ក្នុងសំណុំរឿង ០០៤/២); **E3/2490** (D6.1.337 ក្នុងសំណុំរឿង ០០៤/២); **E3/9750** (D6.1.461 ក្នុងសំណុំរឿង ០០៤/២); **E3/2784, E3/2785** (D6.1.534 ក្នុងសំណុំរឿង ០០៤/២); **E3/2792** (D6.1.541 ក្នុងសំណុំរឿង ០០៤/២); **E3/2990** (D6.1.879 ក្នុងសំណុំរឿង ០០៤/២); **E3/2997** (D6.1.881 ក្នុងសំណុំរឿង ០០៤/២)។

[65] ឯកសារ **D5/1387** ក៏ត្រូវបានកំណត់ថាជា "ចម្លើយសារភាព" ក្នុងសំណុំរឿង ០០៤/២ ប៉ុន្តែវាត្រឹមត្រូវជាងក្នុងការកំណត់អត្តសញ្ញាណជាពាក្យសុំរបស់ជនរងគ្រោះ។ ដូច្នេះ វាត្រូវបានបង្ហាញសម្រាប់ការធ្វើចំណាត់ប្រភេទឡើងវិញក្នុង ឧបសម្ព័ន្ធ ង-៤ ដែលជាកន្លែងត្រូវបានដាក់ជាក្រុមត្រឹមត្រូវជាងជាមួយសម្ភារជនរងគ្រោះនិងដើមបណ្ដឹងរដ្ឋប្បវេណីដែលអាចទទួលយកបាន។

ធិបតេយ្យស្ដីពីបច្ចេកទេសសួរចម្លើយខ្លាំង ឬពួកវាទាក់ទងនឹងស្ថានប័នធ្វើការសម្រេចរបស់ ប.ក.ក និងការពិភាក្សាអំពីគោលនយោបាយរបស់ថ្នាក់ដឹកនាំ។

57. ចំពោះការលើកលែងនេះ ស.ព.អ ផ្ដល់អនុសាសន៍ឲ្យបន្តការសម្ងាត់ចំពោះសៀវភៅកត់ត្រារបស់អ្នកសួរចម្លើយមន្ទីរសន្តិសុខ ដែលរៀបរាប់លម្អិតខ្លឹមសារចម្លើយសារភាពរបស់អ្នកទោស ដែលសន្មតថាបានមកដោយការធ្វើទារុណកម្ម។ ត្រង់នេះ ផលប្រយោជន៍នៃតម្លាភាព មិនមានទម្ងន់ធ្ងន់ខ្លាំងជាងតម្រូវការការពារព័ត៌មានផ្ទាល់ខ្លួនដែលមិនចង់ឲ្យគេដឹងឮ និង/ឬព័ត៌មានអត្តសញ្ញាណដែលមាននៅក្នុងឯកសារទាំងនោះឡើយ[66]។

58. ការអនុវត្តគោលការណ៍ទាំងនេះចំពោះប្រភេទកំណត់ត្រាទាំងអស់នេះ នៅក្នុងសំណុំរឿង ០០៤/២ ស.ព.អ ស្វែងរកឲ្យធ្វើឲ្យទៅជាសាធារណៈនូវឯកសារសម្ងាត់ចំនួន ៣១ ក្នុងចំណោមឯកសារចំនួន ៤៩ ដូចបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ក-៨[67]។ ឯកសារដែលនៅសល់ចំនួន ១៨ ទៀត គឺជាសៀវភៅកត់ត្រារបស់អ្នកសួរចម្លើយមន្ទីរសន្តិសុខ ដែលពិភាក្សាអំពីចំណុចលម្អិតនៃចម្លើយសារភាពដែលតាមការសន្មតបង្កើតឡើងដោយការធ្វើទារុណកម្ម។ ស.ព.អ កត់សម្គាល់ថា កំណត់ត្រាជាក់លាក់ទាំងអស់នេះ មានជាសាធារណៈរួចហើយនៅក្នុងសំណុំរឿង ០០២[68]។ សម្រាប់មូលហេតុដូចបានលើកឡើងមកហើយនេះ គាត់ផ្ដល់អនុសាសន៍ថា អង្គជំនុំជម្រះកែប្រែការធ្វើចំណាត់ប្រភេទសាធារណៈក្នុងសំណុំរឿង ០០២ មកជាសម្ងាត់វិញ ហើយអនុវត្តការធ្វើចំណាត់ប្រភេទនេះចំពោះឯកសារជាក់លាក់ទាំងអស់នេះនៅក្នុងសំណុំរឿងទាំងអស់។

## ៩. *អត្ថបទសារព័ត៌មាន (ផ្នែក I)*

59. សម្ភារក្នុងប្រភេទកំណត់ត្រានេះរួមមាន ទស្សនាវដ្ដី ប.ក.ក អត្ថបទសារព័ត៌មាន និងរបាយការណ៍ប្រតិចារឹកនៃការផ្សាយវិទ្យុ សេចក្ដីថ្លែងការណ៍រដ្ឋាភិបាលកម្ពុជា និងសារព័ត៌មានប្រជាធិបតេយ្យ

---

[66] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៤, ២៤ និង ២៥ *យោងខាងលើ*។

[67] ឧបសម្ព័ន្ធនេះក៏កត់សម្គាល់ផងដែរថាឯកសារមួយណាអាចតម្រូវឲ្យមានការកោសលុប មុនពេលធ្វើឲ្យទៅជាសាធារណៈ។ *សូមមើល* ជើងទំព័រ ៤៥ *យោងខាងលើ*។

[68] ក្នុងសំណុំរឿង ០០២ *សូមមើល* **E3/4092** (D6.1.202 ក្នុងសំណុំរឿង ០០៤/២), **E3/5860** (D6.1.214 ក្នុងសំណុំរឿង ០០៤/២), **E3/2427** (D6.1.217 ក្នុងសំណុំរឿង ០០៤/២), **E3/4095** (D6.1.218 ក្នុងសំណុំរឿង ០០៤/២), **E3/5827** (D6.1.275 ក្នុងសំណុំរឿង ០០៤/២), **E3/4122** (D6.1.297 ក្នុងសំណុំរឿង ០០៤/២)។

ទូរលេខការទូត ស.រ.អ[69] សេចក្តីរាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេស (FBIS) និង អត្ថបទសារព័ត៌មាន ដែលត្រូវបានភ្ជាប់ជាឯកសារសំអាងផ្លូវច្បាប់ ឬឧបសម្ពន្ធទៅនឹងសារណា។ សម្រាប់គោលបំណងនៃការវិភាគនេះ "អត្ថបទសារព័ត៌មាន" ត្រូវបានបំបែកជាពីរផ្នែក៖ ផ្នែកទី១ មានឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ ចំណែកផ្នែកទី២ មានឯកសារនៅក្រោយកាលបរិច្ឆេទ សម័យកម្ពុជាប្រជាធិបតេយ្យ[70]។

60. ដោយមានករណីលើកលែងមួយ ស.ព.អ ផ្តល់យោបល់ថា អត្ថបទសារព័ត៌មានសម័យកាលកម្ពុជា ប្រជាធិតេយ្យ ត្រូវធ្វើឱ្យទៅជាសាធារណៈ។ ដោយសារជាកំណត់ត្រាសហកាលនៃព្រឹត្តិការណ៍ដែល បានកើតឡើងក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ ឬភ្លាមៗមុននោះ ឯកសារទាំងនេះជួយ ពន្យល់ពីព្រឹត្តិការណ៍ទាំងនោះ។ ឯកសារទាំងនេះក៏ផ្តល់ផងដែរនូវភស្តុតាងអំពីការទទួលស្គាល់ និង គោលនយោបាយជាតិរបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្ទុយពីនេះ និងសម្រាប់មូលហេតុ ដូចបានរៀបរាប់ខាងដើម ស.ព.អ មើលមិនឃើញតម្លៃណាក្នុងការធ្វើឱ្យអត្ថបទសារព័ត៌មានដែល ភ្ជាប់ជាឯកសារសំអាងផ្លូវច្បាប់ទាំងនោះ អាចចូលមើលបានជាសាធារណៈទេ និងផ្តល់អនុសាសន៍ ឱ្យរក្សាទុកឯកសារបែបនោះ នៅជាសម្ងាត់ដដែល[71]។

61. ទាក់ទងនឹងសំណុំរឿង ០០៤/២ ស.ព.អ ស្វែងរកឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារ ចំនួន ៥១៩ ក្នុងចំណោមឯកសារសម្ងាត់ចំនួន ៨៦៤ នៅក្នុងប្រភេទកំណត់ត្រានេះ ដូចបានបង្ហាញ នៅក្នុងឧបសម្ពន្ធ ក-៩[72]។

## ១០. ***វិធាន និងបទបញ្ជា***

[69] ស.ព.អ កត់សម្គាល់ថា ការធ្វើឱ្យទូរលេខការទូត ស.រ.អ ទៅជាសាធារណៈអាចត្រូវការការអនុញ្ញាតពីរដ្ឋាភិបាល ស.រ.អ។ ដោយហេតុថា សារទូរលេខដូចគ្នានេះជាឯកសារសាធារណៈនៅលើសំណុំរឿង អ.វ.ត.ក រួចហើយនោះ ស.ព.អ សន្មតថា លក្ខខណ្ឌតម្រូវបែបនេះត្រូវបានបំពេញរួចហើយ ប៉ុន្តែគាត់គ្រាន់តែទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះលើបញ្ហានេះក្រែងលោ បញ្ហានេះវាមិនដូច្នោះ។ ការក្រើនរំលឹកដូចគ្នានេះរួមបញ្ចូលនៅក្នុងឧបសម្ពន្ធពាក់ព័ន្ធដែលភ្ជាប់ទៅនឹងឯកសារដែលស្នើឡើងក្នុង សំណុំរឿង ០០៤/២។

[70] អត្ថបទសារព័ត៌មានក្រោយសម័យកាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញនៅក្នុង ឧបសម្ពន្ធ ឃ-៤ ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៩១ *យោងខាងក្រោម*។

[71] *សូមមើល* កថាខណ្ឌ ៤២ *យោងខាងលើ*។

[72] កត់សម្គាល់ថា មានឯកសារចំនួន ៨៦៣ ត្រូវបានធ្វើចំណាត់ប្រភេទថាជា "អត្ថបទសារព័ត៌មាន" ក្នុងសំណុំរឿង ០០៤/២។ ឯកសារបន្ថែម (ទី៨៦៤) ត្រូវបានធ្វើចំណាត់ប្រភេទតាមឈ្មោះរបស់វានៅក្នុង Zylab ជាជាងតាមប្រភេទរបស់វាទេ (*សូមមើល* **D219/879.1.4**) ប៉ុន្តែសម្រាប់គោលបំណងនៃការវិភាគនេះ វាត្រូវបានដាក់ជាក្រុមជាមួយ "អត្ថបទសារព័ត៌មាន" ផ្សេងទៀត។

62. ប្រភេទកំណត់ត្រានេះមានវិធាន ច្បាប់ សេចក្តីសម្រេច សាលក្រម លិខិតុបករណ៍ច្បាប់ និងសម្ភារផ្សេងទៀត ដែលមាននៅក្នុងផ្នែកសាធារណៈរួចហើយ។ ស.ព.អ ផ្តល់អនុសាសន៍ថា ឯកសារបែបអស់ទាំងនេះគួរធ្វើឱ្យទៅជាសាធារណៈ ប៉ុន្តែតែនៅពេលណាដែលពួកវាមិនត្រូវបានភ្ជាប់ជាឯកសារសំអាងផ្លូវច្បាប់ភ្ជាប់ទៅនឹងសារណាប៉ុណ្ណោះ[73]។

63. សម្រាប់សំណុំរឿង ០០៤/២ ស.ព.អ ស្វែងរកឱ្យធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារចំនួន ១៥ ក្នុងចំណោមឯកសារសម្ងាត់ចំនួន ៦៦៨ នៅក្នុងប្រភេទកំណត់ត្រានេះ។ ឯកសារទាំង ១៥ នេះរួមមាន លក្ខខន្តិកៈ ប.ក.ក និងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ផែនទីតំបន់ និងផែនទីប្រទេសរបស់កម្ពុជា ដែលជួយបញ្ជាក់អត្តន័យទីកន្លែង ដែលមានរៀបរាប់ក្នុងភ័ស្តុតាង និងផែនទីដែលកត់សម្គាល់អំពីទីតាំងមន្ទីរតំបន់របស់ អោ អាន ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[74]។ ឯកសារទាំងនេះមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក-១០។

## ខ. សារណា

64. "សារណា" នៅក្នុងសារពើព័នសាយឡាប មានប្រភេទកំណត់ហេតុចំនួន ១០ ប្រភេទ៖ (១) ញត្តិ (២) សំណើ (៣) សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ (៤) ចម្លើយតប (៥) ការឆ្លើយតប (៦) សេចក្តីសម្រេច (៧) ដីកាសម្រេច (៨) សាលក្រម (៩) កំណត់ហេតុបណ្តឹងឧទ្ធរណ៍ និង(១០) បញ្ជីឯកសារ[75]។

65. សម្រាប់គោលបំណងនៃការវិភាគ ជំនួសឱ្យការដាក់ឯកសារជាក្រុមតាមប្រភេទកំណត់ហេតុនីមួយៗ សារណាគឺមានការយល់បានល្អពេលយើងដាក់តាមលំដាប់លេខរៀងទៅតាមលេខឯកសារ ដោយសារក្រុមនេះពាក់ព័ន្ធនឹងសារណាជាមួយគ្នា[76]។ ការនេះវាជួយក្នុងការសម្រេចចិត្តក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញ ពេលដែលឯកសារខ្លះត្រូវបានធ្វើជាសាធារណៈរួចហើយ ប៉ុន្តែសារណាដែលពាក់ព័ន្ធមិនទាន់បានធ្វើចំណាត់ថ្នាក់ឡើងវិញនៅឡើយ។ ជាឧទាហរណ៍ វាជាការសមហេតុផលក្នុងការធ្វើ

---

[73] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៤២ *យោងខាងលើ*។

[74] ទោះបីជាអង្គហេតុដែលថា ឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនេះ គឺជាផែនទី ពួកវាត្រូវបានកំណត់ឈ្មោះថាជា "វិធាន និងបទបញ្ជា" នៅក្នុង Zylab និងហេតុដូច្នេះត្រូវបានបញ្ចូលក្នុងផ្នែកនៃការវិភាគនេះ។

[75] *សូមមើល* ជើងទំព័រ ៤២ ខាងលើ (កត់សំគាល់ថា មានឯកសារខ្លះនៃបញ្ជីឯកសារនេះមាននៅក្នុងឧបសម្ព័ន្ធ ខ ហើយចំណែកឯកសារដែលនៅសល់គឺមាននៅក្នុងឧបសម្ព័ន្ធ ឃ-៥ និងការពន្យល់អំពីមូលហេតុនៃការបំណែក)។

[76] *សូមមើល* កថាខណ្ឌ ២៨ ខាងលើ។

ចំណាត់ថ្នាក់ឡើងវិញលើចម្លើយតប និងការឆ្លើយតបមួយ ប្រសិនបើញត្តិ និងសេចក្តីសម្រេចដែល ត្រូវគ្នាទាំងពីរ អាចរកបានជាសាធារណៈរួចហើយ។

66. តាមគោលការណ៍ទូទៅ ស.ព.អ សូមផ្តល់អនុសាសន៍ឲ្យដាក់ "សារណា" ទៅជា **សាធារណៈ** នៅពេលណាអាចធ្វើបាន ធ្វើដូច្នេះវានឹងធ្វើឲ្យកំណត់ហេតុកាន់តែមានភាពលេញលេញ ដោយសារយើងមានអង្គច្បាប់និងអង្គហេតុនិងសេចក្តីសម្រេចនៅក្នុងសំណុំរឿង។ ការណ៍នេះវាបំរើឲ្យគោលបំណងដ៏សំខាន់នៃតម្លាភាព ការអប់រំ និងកេរដំណែល។

67. យ៉ាងណាមិញ កង្វល់អំពីសន្តិសុខ និងឯកជនភាព ឬទម្លាប់នៃការអនុវត្តត ម្រូវឲ្យរក្សាទុកសារណាមួយចំនួននៅជាសម្ងាត់។ ឧទាហរណ៍ សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទចែងថា សំណើទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលគិតថា មិនអាចទទួលយកបាន និងសំណើពាក់ព័ន្ធនឹងវិធានការការពារ *ត្រូវតែ* រក្សាទុកជាការសម្ងាត់[77]។ ស.ព.អ សន្និដ្ឋានផងដែរថា មានការប្រើប្រាស់តិចតួចណាស់ក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញ លើសំណើសុំកែតម្រូវឯកសារក្នុងសំណុំរឿង ដោយសារការកែតម្រូវបានអនុវត្តរួចហើយ ហើយសំណៅចាស់ជាទូទៅក៏លែងរកបាននៅក្នុងប្រព័ន្ធសាយឡាប។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចសម្រេចថាតម្លាភាពនៃដំណើរការ អំណោយផលដល់ការធ្វើចំណាត់ថ្នាក់ឡើងវិញលើសំណើទាំងនេះ។ ជាចុងក្រោយ ដូចបានពន្យល់ពីខាងដើម ស.ព.អ យល់ឃើញថា ឯកសារដែលបានភ្ជាប់ជាឯកសារយោងទៅសារណាផ្សេងទៀត គួរតែរក្សាទុកជាការសម្ងាត់[78]។

68. ក្នុងសំណុំរឿង ០០៤/២ ស.ព.អ ស្នើធ្វើចំណាត់ប្រភេទឡើងវិញលើសារណាសម្ងាត់ចំនួន ៧២៣ ដូចបានរៀបរាប់លម្អិតក្នុងឧបសម្ព័ន្ធ ខ[79]។ ឯកសារដែលបានស្នើភាគច្រើន គឺជាឯកសារដែលបានដាក់ជូន ឬចេញមុនការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ និងដោយសារមានសេចក្តីសម្រេចរបស់ អ.ប.ជ អំពីការធ្វើចំណាត់ប្រភេទឡើងវិញនាពេលថ្មីៗនេះ ដែលបានធ្វើឲ្យទៅជាសាធារណៈចំពោះសំណុំរឿង ០០៤ និង/ឬ ០០៤/១ ប៉ុន្តែមិនបានធ្វើទៅលើសំណុំរឿង ០០៤/២[80]។

[77] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ២២ ខាងលើ (បញ្ជាក់ន័យដើម)។

[78] *សូមមើល* កថាខណ្ឌ ៤២ ខាងលើ។

[79] កត់សំគាល់ថា សំណើទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ដែលយល់ថាអាចទទួលយកបាននៅក្នុងសំណុំរឿង ០០៤/២ នោះ ត្រូវបានដាក់ជាក្រុមជាមួយនឹងសម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ពន្ធសម្រាប់គោលបំណងនៃការធ្វើចំណាត់ប្រភេទឡើងវិញនៅក្នុងឧបសម្ព័ន្ធ ង-៤ ដូចបានពិភាក្សាខាងក្រោម។

[80] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ១៦ ខាងលើ។

ឯកសារផ្សេងទៀតដែលបានស្នើឲ្យធ្វើចំណាត់ប្រភេទឡើងវិញរួមមាន សារណាជាក់លាក់ចំពោះសំណុំរឿង អោ អាន។ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ *មិនបាន* ស្នើសុំសម្រាប់ប្រភេទឯកសារដែលមានចរិកលក្ខណៈជាឯកសាររដ្ឋបាលជាចំបង ដែលបានភ្ជាប់ជាមួយសារណាផ្សេងទៀតជាប្រភពឯកសារយោង ឬឧបសម្ព័ន្ធ ឬដែលពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនអាចទទួលយកបាន[81] នោះទេ។

## គ. ឯកសារពាក់ព័ន្ធនឹងដំណើរការស៊ើបសួរ

69. ប្រភេទកំណត់ហេតុសាយឡាបដែលពាក់ព័ន្ធនឹងដំណើរការស៊ើបសួរក្នុងសំណុំរឿង មាន (១) លិខិត (២) អនុស្សរណៈ (៣) ដីកាចាត់ឲ្យស៊ើបសួរជំនួស (៤) ដីកាកោះ (៥) ផែនទី និង (៦) រូបថត។ ឯកសារទាំងនេះបង្ហាញអំពីជម្រៅ និងទំហំនៃកិច្ចស៊ើបសួរ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងដែលតម្រូវដើម្បីចោទប្រកាន់សំណុំរឿងទាំងនេះ។

70. តាមគោលការណ៍ទូទៅ ឯកសារក្នុងជំពូកដ៏ធំដូចនេះ គួររក្សាទុកជា **ការសម្ងាត់**។ ភាគច្រើនគឺជាឯកសាររដ្ឋបាលដែលមានតម្លៃសំខាន់តិចតួច ឬឯកសារដែលទាមទារការការពារដោយសារតែមានព័ត៌មានលម្អិតសម្ងាត់ទាក់ទននឹងតម្រុយនៃកិច្ចស៊ើបសួរ ឬសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីសក្ដានុពល។ ទោះជាយ៉ាងណា ការធ្វើឲ្យឯកសារស៊ើបអង្កេតទៅជាសាធារណៈ តាមលទ្ធភាពអាចធ្វើបាននឹងជួយក្នុងការលើកកម្ពស់តម្លៃ និងភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ព្រមទាំងផ្ដល់អំពីទិដ្ឋភាពនៃការអនុវត្តនៃស៊ើបសួរល្អ អាចជួយបង្កើនគុណភាពយុត្តិធម៌ដែលផ្ដល់ជូនដោយប្រពន្ធច្បាប់ជាតិរបស់កម្ពុជា។

71. ភាគច្រើនៃឯកសារស៊ើបអង្កេតក្នុងសំណុំរឿង ០០៤, ០០៤/១ និង ០០៤/២ គឺមិនពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរនីមួយៗរៀងៗខ្លួននោះទេ អាស្រ័យដោយ លក្ខណៈនៃការចែករំលែកនៃសំណុំរឿងនៅក្នុងចំណោមជនជាប់ចោទទាំងបី មុនពេលបំបែកកិច្ចដំណើរការនីតិវិធី។ ស.ព.អ សន្និដ្ឋានថា ឯកសារស៊ើបអង្កេតដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ អោ អាន ដែលបានធ្វើឲ្យទៅជាសាធារណៈនៅក្នុងសំណុំ

[81] *សូមមើល* ឯកសារ **D362.2** ឧបសម្ព័ន្ធ ខ: ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានប្រកាសថា មិនអាចទទួលយកបាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

រឿង ០០៤/២ រួចហើយ មិនគួរធ្វើឲ្យទៅជាសាធារណៈនៅក្នុងសំណុំរឿង ០០៤ ឬ ០០៤/១ ឡើយ វៀរលែងតែឯកសារទាំងនោះមានការពាក់ព័ន្ធនៅទីនោះដែរ[82]។

72. ដោយមានការយកចិត្តក្នុងចិត្តជានិច្ចពីគោលការណ៍ទាំងនេះ ស.ព.អ សូមផ្ដល់អនុសាសន៍ដូចតទៅ។

## ១. *លិខិត*

73. ប្រភេទកំណត់ហេតុនេះមានព័ត៌មានឆ្លើយឆ្លងដែលអាចបែងចែកជាបីជំពូក។ ទីមួយ គឺឯកសារដែលទទួលបានការការពារដែលមិនអាចប្រកែកបាន និងគួរតែរក្សាទុកជាការសម្ងាត់។ ទីពីរ គឺជាឯកសារដែលអាចធ្វើឲ្យទៅជាសាធារណៈដោយសុវត្ថិភាព និងទីបី គឺជាឯកសារដែលអាចដាក់ចូលក្នុងផ្លូវណាមួយនៃផ្លូវទាំងពីរខាងលើ គឺអាស្រ័យលើអង្គជំនុំជម្រះកំណត់លើផលប្រយោជន៍ប្រគួតប្រជែងរបស់វា។

74. ឯកសារដែលធ្លាក់ចូលក្នុងជំពូកទីមួយ គួរតែរក្សាទុកជាការសម្ងាត់ ដែលរួមមានរបាយការណ៍របស់អង្គភាព WESU សំណើសុំជំនួយកិច្ចស៊ើបសួរ ឯកសារឆ្លើយឆ្លងនៃកិច្ចស៊ើបសួរស្របតាមវិធាន៣៥ លិខិតធានា លិខិតមរណភាព លិខិតពាក់ព័ន្ធនឹងការបញ្ជូនឯកសារ(ដែលមានព័ត៌មានលម្អិតនៃទីតាំងរបស់បុគ្គលជាអ្នកទទួល) និងលិខិតពាក់ព័ន្ធបុគ្គលិក ក.ស.ច.ស[83]។ សម្រាប់ជំពូកទីពីរ ស.ព.អ សន្និដ្ឋានថា ឯកសារដែលសមស្របសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញ រួមមាន លិខិតសម័យកម្ពុជាប្រជាធិបតេយ្យ បទបញ្ជា និងសេចក្ដីរាយការណ៍ ព្រមទាំងសេចក្ដីឆ្លើយឆ្លងទៅមករបស់ ស.ច.ស.អ។

75. ឯកសារដែលធ្លាក់ចូលក្នុងជំពូកទីបី គឺមានលក្ខណៈជាឯកសាររដ្ឋបាលច្រើនជាង។ ឯកសារទាំងនេះរួមមាន លិខិតទាក់ទងនឹងការធ្វើបទបង្ហាញផ្លូវច្បាប់របស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ លិខិតប្រគល់សិទ្ធិអំណាច ការដកខ្លួនចេញពីកិច្ចដំណើរការនីតិវិធី ការបញ្ជូនឯកសារទៅក្នុងសំណុំរឿង ០០៣ និង ០០៤ សេចក្ដីជូនដំណឹងអំពីស្ថានភាពនៃការផ្លាស់ប្តូរ (ផ្លាស់ប្តូរពីដើមបណ្ដឹងទៅជាអ្នកដាក់ពាក្យសុំ)។ ទោះជាអាចថានឹងមានតម្លៃក្នុងការអនុញ្ញាតផ្ដល់លទ្ធភាពចូលមើលឯកសាររដ្ឋបាលដូច្នេះដល់អ្នកដែលមានផលប្រយោជន៍ក្នុងដំណើរការក៏ពិតមែន សម្រាប់ ស.ព.អ យល់ថា តម្លៃនេះគឺតិចតួចណាស់។ ទោះជាយ៉ាងណា ប្រសិនបើអង្គជំនុំជម្រះសម្រេចថា ផលប្រយោជន៍នៃតម្លាភាព

[82] ការនេះរួមមាន របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ដែលបានពិភាក្សារួចហើយក្នុងកថាខណ្ឌ ៤៣ ខាងលើ។

[83] *សូមមើល* កថាខណ្ឌ ៤, ២២-២៤ ខាងលើ។

មានយុត្តិកម្មលើការធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះឯកសាររដ្ឋបាលដូច្នេះ សំខាន់ត្រូវកត់សំគាល់ថា ឯកសារខ្លះមានអាសយដ្ឋាន និងលេខអត្តសញ្ញាណផ្ទាល់ខ្លួន ដែលទាមទារឱ្យមានការកោសលុប។ លើសពីនេះ បើសិនលិខិតមានការទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី នោះការធ្វើចំណាត់ថ្នាក់ឡើងវិញអាចនឹងសមស្របតែនៅពេលណាគិតថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងអាចទទួលយកបានដោយ ស.ច.ស.អ ប៉ុណ្ណោះ និងជាថ្មីម្តងទៀត គឺទាល់តែឯកសារទាំងនេះមានការកោសលុប មុនពេលធ្វើឱ្យទៅជាសាធារណៈ[84]។ ហេតុដូចនេះ ស.ព.អ សូមធ្វើការកំណត់អត្តសញ្ញាណបញ្ហាទាំងនេះសម្រាប់ឱ្យ អ.ជ.ត.ក ពិចារណា និងអនុវត្តដូចៗគ្នា។

76. ក្នុងការអនុវត្តអភិក្រមខាងលើក្នុងសំណុំរឿង ០០៤/២ ស.ព.អ សូមស្នើឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ១៧៥ នៅក្នុងចំណោម "លិខិត"សម្ងាត់ចំនួន ៦.៣៨២ ដូចបានពិពណ៌នាលម្អិតក្នុងឧបសម្ព័ន្ធ គ-១[85]។ ឯកសារទាំងនេះរួមមាន កំណត់ហេតុសម័យកម្ពុជាប្រជាធិបតេយ្យ សេចក្តីឆ្លើយឆ្លងទាក់ទងនឹងការធ្វើបទបង្ហាញផ្លូវច្បាប់របស់ អោ អាន និងសេចក្តីជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងនាមជាជនសង្ស័យ និងជនត្រូវចោទ ព្រមទាំងលិខិតដែលបានដាក់ទៅក្នុងសំណុំរឿងតាំងពីមុនការបំបែកកិច្ចដំណើរការនីតិវិធីដែល អ.ប.ជ បានធ្វើទៅជាសាធារណៈនៅក្នុងសំណុំរឿង ០០៤ និង/ឬ ០០៤/១[86]។

## ២. *អនុស្សរណៈ*

77. ប្រភេទកំណត់ហេតុនេះមានអនុស្សរណៈរបស់អង្គភាព WESU និងអង្គភាពគាំពារជនរងគ្រោះ ("VSS") ទាក់ទងនឹង និង/ឬ មានព័ត៌មានផ្ទាល់ខ្លួនសម្ងាត់អំពីសាក្សី ឬជនរងគ្រោះ គឺអនុស្សរណៈដែលពិភាក្សាអំពីបញ្ហាបុគ្គលិកនិងថវិកា អនុស្សរណៈទាក់ទងនឹងកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥ និងអនុស្សរណៈពាក់ព័ន្ធនឹងបញ្ហារដ្ឋបាលដែលតាមការយល់ឃើញរបស់ ស.ព.អ មានតម្លៃតិចតួច ឬគ្មានតម្លៃសោះសម្រាប់សាធារណជន (ដូចជាការពន្យារដីកាចាត់ឱ្យស៊ើបសួរជំនួស ជាដើម)។ ដើម្បីអនុលោមភាពតាមគោលការណ៍ទូទៅដូចបានជម្រាបជូនខាងលើ[87] ស.ព.អ ផ្តល់អនុសាសន៍

[84] *សូមមើល* កថាខណ្ឌ ២២ ខាងលើ។ ឯកសារ **D362.1** ឧបសម្ព័ន្ធ ក: ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្រកាសថា អាចទទួលយកបាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[85] "លិខិត" បន្ថែមត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធសម្ភារដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ (ឧបសម្ព័ន្ធ ង-៤) ដែលត្រូវបានដាក់តាមលំដាប់ក្រុមជាមួយនឹងឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ។

[86] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ១៦ ខាងលើ។

[87] *សូមមើល* កថាខណ្ឌ ៧០ ខាងលើ។

ថា ឯកសារទាំងនេះនៅតែរក្សាទុកចំណាត់ថ្នាក់នៅជាការសម្ងាត់។ យ៉ាងណាមិញ មានអនុស្សរណៈខ្លះអាចមានយុត្តិកម្មសម្រាប់ការលើកលែងពីវិធាន ដូចជាអនុស្សរណៈតុលាការទាក់ទងការអនុវត្តកិច្ចស៊ើបសួរ ឬសេចក្ដីណែនាំដែលបានធ្វើឡើងទៅកាន់ភាគីក្នុងរឿងក្ដី។

78. នៅក្នុងសំណុំរឿង ០០៤/២ ស.ព.អ សូមស្នើឱ្យធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារសម្ងាត់ចំនួន ២៤ ពីក្នុងចំណោមឯកសារសម្ងាត់ ២៨១ ដែលបានពន្យល់លម្អិតនៅក្នុងឧបសម្ព័ន្ធ គ-២។ ឯកសារទាំងនេះរួមមាន អនុស្សរណៈអន្តរការិយាល័យតុលាការដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤/២ (រួមមាន សេចក្ដីណែនាំពី ស.ច.ស ទៅអ្នកស៊ើបអង្កេតទាំងអស់ ទាក់ទងនឹងក្រមសីលធម៌ក្នុងសម្ភាសន៍សាក្សី) អនុស្សរៈឆ្នាំ១៩៧៦ ពីទីប្រឹក្សាសន្តិសុខជាតិ ស.រ.អា ដែលលែងជាប់ចំណាត់ថ្នាក់ ជូនប្រធានាធិបតី ស.រ.អា Gerald Ford ទាក់ទងនឹងជីវិតនៅកម្ពុជា និងតារាងកែពាក្យខុសនៃសេចក្ដីសម្រេចមួយដែលបានធ្វើចំណាត់ប្រភេទជាសាធារណៈរួចហើយ។

## ៣. ***ដីកាចាត់ឱ្យស៊ើបសួរជំនួស***

79. "ដីកាចាត់ឱ្យស៊ើបសួរជំនួស" ចាត់តាំងការងារស៊ើបសួរជាក់លាក់ដល់អ្នកស៊ើបអង្កេត ក.ស.ច.ស ហើយជាញឹកញាប់តែងមានព័ត៌មានដែលចាំបាច់ត្រូវរក្សាការការពារ។ ដោយធ្វើការថ្លឹងថ្លែងទៅលើគោលការណ៍ទូទៅនៃភាពសម្ងាត់សម្រាប់ឯកសារស៊ើបអង្កេត ធៀបនឹងផលប្រយោជន៍នៃតម្លាភាព ស.ព.អ សូមផ្ដល់អនុសាសន៍ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ១១ នៃឯកសារសម្ងាត់ចំនួន ៦៩ នៅក្នុងសំណុំរឿង ០០៤/២។ ការណ៍នេះអនុញ្ញាតឱ្យការងារស៊ើបសួរជាក់លាក់ដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរលើ អោ អាន ដែលមិនមានព័ត៌មានរសើប តម្រូវឱ្យមានការកោសលុបទេ វៀរលែងតែមានការកត់សំគាល់ផ្សេងពីនេះ[88]។ ឯកសារមានការពន្យល់លម្អិតនៅក្នុងឧបសម្ព័ន្ធ គ-៣។

## ៤. ***ដីកាកោះ***

80. ភាគច្រើននៃឯកសារក្នុងប្រភេទកំណត់ហេតុនេះ គឺជាដីកាកោះ ដែលបានបញ្ជូនទៅអនាគតសាក្សីសម្រាប់ការសម្ភាសន៍ជាមួយ ក.ស.ច.ស។ សម្រាប់រឿងក្ដីដែលនឹងមិនដំណើរការទៅកាន់ការជំនុំជម្រះ ឯកសារទាំងនេះកំណត់អត្តសញ្ញាណបុគ្គលម្នាក់ៗដែលមានការរំពឹងទុកអំពីឯកជនភាព ពេលពួកគេសហការក្នុងកិច្ចស៊ើបសួរ។ ឯកសារទាំងនេះក៏មានអាសយដ្ឋានផ្ទាល់ខ្លួនដែលត្រូវតែរក្សាទុក

[88] តាមទស្សនៈរបស់ ស.ព.អ ទីតាំងពិស្ដារចាំបាច់ត្រូវតែកោសលុបនៅលើទំព័រ ២ នៃឯកសារ **D241** ដូចបានកត់សំគាល់នៅក្នុងឧបសម្ព័ន្ធផងដែរ។

ជារឿងឯកជន[89]។ អាស្រ័យហេតុនេះ ស.ព.អ សូមផ្តល់អនុសាសន៍ឲ្យរក្សាទុកឯកសារទាំងនេះជាការសម្ងាត់ដដែល ដោយសារភាគច្រើនវាជាប្រភេទឯកសាររដ្ឋបាល និងមានហានិភ័យអាចគ្រោះថ្នាក់ បើសិនជាធ្វើឲ្យទៅជាសាធារណៈ ដែលមានទម្ងន់ស្រាលជាងតម្លៃដ៏តិចតួចដែលឯកសារទាំងនេះអាចផ្តល់ឲ្យក្នុងលើកកម្ពស់តម្លាភាព។

81. យ៉ាងណាមិញ ស.ព.អ *ពិតណាស់* ផ្តល់អនុសាសន៍ឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារសម្ងាត់ចំនួន ៨ នៃឯកសារសម្ងាត់ ៦៦៥ នៅក្នុងប្រភេទកំណត់ហេតុនេះក្នុងសំណុំរឿង ០០៤/២។ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ គ-៤ ឯកសារដែលបានស្នើនេះគឺជាដីកាកោះហៅ អោ អាន របស់ ក.ស.ច.ស និង/ឬ មេធាវីរបស់គាត់ឲ្យចូលបង្ហាញខ្លួនលើកដំបូង និងការចូលបង្ហាញខ្លួនបន្តបន្ទាប់នៅចំពោះមុខ ស.ច.ស.អ ដើម្បីធ្វើការចោទប្រកាន់[90]។ ឯកសារទាំងនេះ គឺមានការពាក់ព័ន្ធ សារសំខាន់ និងផលប្រយោជន៍ខ្លាំងចំពោះសំណុំរឿង។ ស.ព.អ *មិន* ស្នើឲ្យធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារកោះហៅ អ៊ឹម ចែម និង យឹម ទិត្យ ឲ្យចូលបង្ហាញខ្លួននៅចំពោះមុខ អ.ស.ច.ស ទេ ដោយសារឯកសារទាំងនោះមានភាពសមស្របសម្រាប់ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ តាមសំណុំរឿងនីមួយៗច្រើនជាង[91]។

## ៥. ***ផែនទី***

82. ឯកសារទាំងនេះរួមមាន ផែនទីប្រទេសសម័យកម្ពុជាប្រជាធិបតេយ្យ គំនូសវាស់ទីតាំងឧក្រិដ្ឋកម្មដែលបានគូសដោយសាក្សី និងផែនទីតំបន់និងជាតិដែលមានកាលបរិច្ឆេទក្រោយរបបនេះ និងជួយដល់ការយល់ដឹងអំពីទីកន្លែងដែលបាននិយាយនៅក្នុងភស្តុតាងសក្ខីកម្ម និងឯកសារ រួមទាំងការវាយប្រហារក្នុងលក្ខណៈរាលដាល និងជាប្រព័ន្ធ និងផ្លូវនៃការជម្លៀសដោយបង្ខំ។ ជាគោលការណ៍ទូទៅ ស.ព.អ សូមផ្តល់អនុសាសន៍ឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញលើផែនទី ទៅជាសាធារណៈ។

83. ក្នុងសំណុំរឿង ០០៤/២ ស.ព.អ សូមស្នើឲ្យធ្វើចំណាត់ប្រភេទឡើងវិញលើផែនទីសម្ងាត់ ១២១ ក្នុងចំណោមផែនទីសម្ងាត់ ១៧៥ ដូចបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ គ-៥។ ប្រសិនបើ អ.ជ.ត.ក កំណត់ថា ផែនទីទាំងអស់នៅក្នុងសំណុំរឿងនេះគួរធ្វើឲ្យទៅជាសាធារណៈទាំងអស់ នោះផែនទីទាំង

---

[89] *សូមមើល* ជើងទំព័រ ១០ និងកថាខណ្ឌ ២២-២៤ ខាងលើ ទាក់ទងនឹងការការពារព័ត៌មានទំនាក់ទំនង។

[90] កត់សំគាល់ថា ព័ត៌មានទំនាក់ទំនងពិស្តារអំពី "ទីលំនៅបច្ចុប្បន្ន" គួរតែកោសលុប ដូចបានបញ្ជាក់ចំៗក្នុងឧបសម្ព័ន្ធ។

[91] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៧១ ខាងលើ។

១៧៥ គឺសុទ្ធតែអាចធ្វើចំណាត់ថ្នាក់ឡើងវិញដោយសុវត្ថិភាពទាំងអស់ ដោយសារឯកសារដែលនៅសល់ គឺគ្រាន់តែជាផែនទីធម្មតាទាក់ទងនឹងកិច្ចស៊ើបសួរ អ៊ឹម ចែម និង យឹម ទិត្យ។

## ៦. *រូបថត*

84. ប្រភេទកំណត់ហេតុនេះរួមមាន រូបថតដែលបានបង្ហាញសាក្សីសក្ខីភាពដែលបានសួរដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដើម្បីកំណត់អត្តសញ្ញាណមនុស្សនៅក្នុងរូបថត (បន្ទាប់មក រូបថតក៏បានភ្ជាប់ទៅនឹងកំណត់ហេតុ)។ ឯកសារក៏រួមបញ្ចូលផងដែរនូវរូបថតភាគីដើមបណ្តឹងរដ្ឋប្បវេណីសក្ខីភាព រូបថតទីតាំងឧក្រិដ្ឋកម្ម រូបថតសៀវភៅ និងរូបថតពីឯកសារអត្តសញ្ញាណកម្មផ្សេងទៀត។ តាមគោលការណ៍ទូទៅ ស.ព.អ ផ្តល់អនុសាសន៍ឱ្យធ្វើឱ្យរូបថតទាំងនេះទៅជាសាធារណៈ លើកលែងតែមានកង្វល់អំពីឯកជនភាព ឬការប៉ះពាល់ផ្លូវច្បាប់ ដូចជាច្បាប់ស្តីពីសិទ្ធិចម្លងដែលចែងផ្សេងពីនេះ។

85. ក្នុងសំណុំរឿង ០០៤/២ ស.ព.អ សូមស្នើឱ្យធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារសម្ងាត់ ៨៥ ក្នុងចំណោមឯកសារសម្ងាត់ ៦៣៩ ក្នុងប្រភេទកំណត់ហេតុនេះដូចបានរៀបរាប់លម្អិតក្នុងឧបសម្ព័ន្ធ គ-៦។ សម្ភារដែលបានស្នើនេះរួមមាន រូបថតជនសង្ស័យដើមទាំងបីនៅក្នុងសំណុំរឿង ០០៤ និង រូបថតរបាយការណ៍កំណត់អត្តសញ្ញាណទីតាំង ដែលចងក្រងជាឯកសារនូវទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០៤/២[92]។ ស.ព.អ *មិន* ស្នើឱ្យធ្វើចំណាត់ប្រភេទឡើងវិញលើរូបថតរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីសក្ខីភាព រូបថតដែលមាននៅក្នុងសៀវភៅដែលទទួលបានការការពារតាមច្បាប់ស្តីពីសិទ្ធិចម្លង រូបថតដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៤ ឬ ០០៤/១ ឬ រូបថតមនុស្សដែលបានសួរឱ្យសាក្សីកំណត់អត្តសញ្ញាណទេ (ដែលបន្ទាប់មកត្រូវបានភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់ពួកគេ)។

## ឃ. <u>ការស្រាវជ្រាវ និងឯកសារយោង</u>

---

92 ក្នុងកិច្ចប្រឹងប្រែងធ្វើចំណាត់ប្រភេទឡើងវិញសម្រាប់សំណុំរឿង ០០៤ និង ០០៤/១ ស.ព.អ សូមឱ្យអង្គជំនុំជម្រះយោងដោយផ្ទាល់ទៅរកជើងទំព័រ៥៦ ខាងលើ ដែលបានចែងអំពីបញ្ហើលម្អិតគ្មានសេសសល់នូវរបាយការណ៍កំណត់អត្តសញ្ញាណទីតាំងឧក្រិដ្ឋកម្មដែលមាននៅក្នុងសំណុំរឿងទាំងនោះ (រួមទាំងរបាយការណ៍ដែលត្រូវបានច្រានចោលជាបន្តបន្ទាប់នាពេលក្រោយមក នៅពេលដែលវិសាលភាពនៃកិច្ចស៊ើបសួរត្រូវបានបង្រួមកាន់តែតូច អនុលោមតាមវិធាន ៦៦ស្ទួន និង៦៧) ដើម្បីងាយស្រួលកំណត់អត្តសញ្ញាណថាតើ រូបថតមួយណាពាក់ព័ន្ធទៅនឹងសំណុំរឿងនោះ។

86. ឯកសារក្នុងជំពូកនេះ គឺមានសមាសភាពដូចតទៅ៖ (១) អត្ថបទស្រាវជ្រាវជាន់ខ្ពស់ (២) សៀវភៅ (៣) របាយការណ៍វិភាគ(កោសលវិច្ឆ័យ) (៤) អត្ថបទសារព័ត៌មាន (ផ្នែក II) និង (៥) បញ្ជីឯកសារ។ ជាចំបង ឯកសារទាំងនេះគឺជាកិច្ចការរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងអ្នកសារព័ត៌មានដែលជួយពន្យល់អំពីទិដ្ឋភាពសំខាន់ៗនៃរបបកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយរបស់របបនេះ។ ជាបន្ទាប់បន្សំ ឯកសារទាំងនេះ គឺជាបញ្ជីឈ្មោះប្រភពឯកសារយោង ដែលគាំទ្រចំពោះអំណះអំណាងអង្គច្បាប់ និងអង្គហេតុដែលបានធ្វើនៅក្នុងសំណុំរឿងនេះ។ ការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារទាំងពីរក្រុម នឹងជួយពន្លឿនដល់គោលបំណងនៃតម្លាភាព ការអប់រំ និងកេរដំណែលរបស់តុលាការ។ អាស្រ័យហេតុនេះ ស.ព.អ សូមផ្តល់អនុសាសន៍ថា តាមគោលការណ៍ទូទៅ គឺធ្វើឱ្យកំណត់ហេតុទាំងនេះទៅជា**សាធារណៈ** វៀរលែងតែធ្វើដូច្នេះវានឹងរំលោភលើច្បាប់ស្តីពីសិទ្ធិចម្លងដែលការពារការប្រើប្រាស់ឯកសារទាំងនេះ[93]។

## ១. *អត្ថបទសិក្សាស្រាវជ្រាវជាន់ខ្ពស់*

87. ប្រភេទកំណត់ហេតុនេះ មានអត្ថបទជាលាយលក្ខណ៍អក្សររបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់លើប្រធានបទដូចជា អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា និងការប៉ុនប៉ងធ្វើរដ្ឋប្រហារដែលគេចោទថា ពាក់ព័ន្ធនឹង កុយ ធួន[94]។ ក្នុងសំណុំរឿង ០០៤/២ ស.ព.អ សូមស្នើឱ្យធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារសម្ងាត់ចំនួន ៦ ក្នុងចំណោមឯកសារសម្ងាត់១២ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ឃ-១ និងសុទ្ធតែអាចរកជាបានជាសាធារណៈទាំងអស់ (ដូចបានពន្យល់លម្អិតនៅក្នុងឧបសម្ព័ន្ធ) ហើយពាក់ព័ន្ធនឹងការស៊ើបសួរ អោ អាន។ ស.ព.អ *មិន* ស្នើឱ្យធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារដែលនៅសល់ទេ ដោយសារឯកសារទាំងនេះ ត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិចម្លង។

## ២. *សៀវភៅ*

---

[93] *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ F30/2 គោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ៧(ង) ដែលចែងថា ឯកសារសាធារណៈ "មិនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនោះទេ ប្រសិនបើឯកសារទាំងនោះ [...] ត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិចម្លងជាធរមាន"។

[94] កុយ ធួន គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមានតួនាទីទទួលខុសត្រូវលើក្រសួងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិតេយ្យផងដែរ និងធ្វើជាលេខាភូមិភាគឧត្តររហូតមុនពេលត្រូវបានចាប់ខ្លួនដោយចោទថាជាជនសង្ស័យក្នុងអំពើក្បត់ នៅពេលចាប់ផ្តើមការបោសសម្អាតលើពួកកម្មាភិបាលភូមិភាគឧត្តរ(ចាស់)។ ពួកកម្មាភិបាលទាំងនេះត្រូវបានជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី ដែលរួមមានទាំង អោ អាន ផង។

88. ឯកសារភាគច្រើននៅក្នុងប្រភេទកំណត់ហេតុនេះ គឺជាឯកសារសហកាលិកកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើចំណាត់ថ្នាក់រួចហើយជាសាធារណៈក្នុងសំណុំរឿងផ្សេងទៀត និង/ឬ មិនមានព័ត៌មានដែលតម្រូវឱ្យមានការការពារ។ ឯកសារដែលនៅសល់រួមមាន សៀវភៅអំពីបញ្ហាផ្សេងៗដូចជា ការរៀបការដោយបង្ខំ និងអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រះពុទ្ធសាសនានៅក្រោម ប៉ុល ពត និងការជម្រុញទឹកចិត្តរបស់ថ្នាក់ដឹកនាំក្នុងការសម្លាប់មនុស្សដែលបានកើតឡើង[95]។ ដូចបានជម្រាបជូនខាងលើ ស.ព.អ សូមផ្តល់អនុសាសន៍ឱ្យធ្វើឱ្យសៀវភៅទាំងនេះទៅជាសាធារណៈ វៀរលែងតែច្បាប់ស្តីពីសិទ្ធិចម្លងចែងផ្សេងពីនេះ[96]។

89. ក្នុងការអនុវត្តគោលការណ៍ទាំងនេះក្នុងសំណុំរឿង ០០៤/២ ស.ព.អ សូមស្នើឱ្យធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារសម្ងាត់ចំនួន ៧០ ក្នុងចំណោមឯកសារសម្ងាត់ ៣១១ នៅក្នុងប្រភេទកំណត់ហេតុនេះ ដូចមានចែងកំណត់ក្នុងឧបសម្ព័ន្ធ ឃ-២។ សម្រាប់ជាសេចក្តីយោងរបស់អង្គជំនុំជម្រះ ឧបសម្ព័ន្ធកំណត់អត្តសញ្ញាណ ប្រសិនបើឯកសារដែលបានស្នើធ្វើចំណាត់ប្រភេទឡើងវិញមិនមែនជាឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ នោះគឺជាឯកសារដែលអាចរកបានជាសាធារណៈនៅលើអនឡាញ។ជាចុងក្រោយ ស.ព.អ សូមផ្តល់អនុសាសន៍ឱ្យអង្គជំនុំជម្រះពិចារណាធ្វើចំណាត់ប្រភេទត្រឡប់ទៅរកការសម្ងាត់ឡើងវិញ ចំពោះសៀវភៅណាដែលត្រូវបានធ្វើឱ្យទៅជាសាធារណៈនៅក្នុងសំណុំរឿង ០០១ និង ០០២ ដែលមានការការពារដោយច្បាប់ស្តីពីសិទ្ធិចម្លង ហើយដែលមិនមែនជាករណីលើកលែងក្នុង "ការប្រើប្រាស់ត្រឹមត្រូវយុត្តិធម៌"[97]។

---

[95] មួយចំណែកតូចនៃឯកសារដែលនៅសល់គឺជា "សៀវភៅ" ដែលបានភ្ជាប់ជាប្រភពឯកសារយោងទៅនឹងសារណាជាច្រើន។ ដូចបានកត់សំគាល់នៅកន្លែងផ្សេងទៀតក្នុងសំណើនេះ (ឧទា កថាខណ្ឌ ៤២ ខាងលើ) ស.ព.អ មិនស្នើធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារទាំងនេះទេ។

[96] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៨៦ ខាងលើ។

[97] នៅក្នុងការវិភាគរបស់ខ្លួនលើឯកសារនៅក្នុងសំណុំរឿង ០០៤/២ ស.ព.អ បានកត់សំគាល់ឃើញថា "សៀវភៅ" ដូចតទៅត្រូវបានធ្វើចំណាត់ប្រភេទជាសាធារណៈនាពេលបច្ចុប្បន្ននៅក្នុងសំណុំរឿង ០០២។ ខណៈដែលសម្រង់ពីសៀវភៅទាំងនេះដែលបានបង្ហាញជាភ័ស្តុតាងនៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការអាចជាករណីលើកលែងក្នុង "ការប្រើប្រាស់ត្រឹមត្រូវយុត្តិធម៌"ក៏ដោយ តែយើងមិនអាចនិយាយដូច្នេះបានទេសម្រាប់សៀវភៅដែលបានធ្វើទៅជាសាធារណៈទាំងមូល។ ហេតុដូចនេះ ស.ព.អ សូមផ្តល់អនុសាសន៍ឱ្យរក្សាទុកឋានៈជាសាធារណៈរបស់វាឱ្យនៅដដែលនៅក្នុងសំណុំរឿង ០០២ (ហើយអនុវត្តសេចក្តីសម្រេចដូចៗគ្នានៅពេលឯកសារដដែលបង្ហាញខ្លួននៅលើសំណុំរឿងផ្សេង)៖ ឯកសារ E3/9, E3/14, E3/16, E3/17, E3/18, E3/20 (E3/510 ក្នុងសំណុំរឿង ០០១), E3/22, E3/29, E3/48, E3/49, E3/1593, E3/1683, E3/1684 និង E3/1693 (E3/427 ក្នុងសំណុំរឿង ០០១), E3/1690, E3/1757, E3/1794, E3/1815, E3/1818 (E3/523 ក្នុងសំណុំរឿង ០០១), E3/1820, E3/1822 (E3/404 ក្នុងសំណុំរឿង ០០១), E3/2120, E3/2121 (E3/48 ក្នុងសំណុំរឿង ០០១), E3/2376 (E3/193

### ៣. *វបាយការណ៍វិភាគ*

90. ឯកសារនៅក្នុងប្រភេទកំណត់ត្រានេះ រួមមានឯកសារ អ.ស.ប ពីសម័យកម្ពុជាប្រជាធិបតេយ្យ ប្រវត្តិគណៈបក្សខ្មែរកុម្មុយនីស និងការវិភាគ និងរបាយការណ៍របស់អ្នកស្រាវជ្រាវជាក់ខ្ពស់ ទាក់ទងនឹងរចនាសម្ព័ន្ធអំណាចរបស់ ប.ក.ក ជនជាតិចាម និងអំពើហិង្សាលើផ្លូវភេទ។ ក្នុងសំណុំរឿង ០០៤/២ ស.ព.អ ស្នើសុំឲ្យធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារសម្ងាត់ចំនួន ៣៣ ក្នុងចំណោមឯកសារចំនួន ៨៣ ដូចបានកំណត់អត្តសញ្ញាណក្នុងឧបសម្ព័ន្ធ ឃ-៣។ ស.ព.អ *មិន* ស្វែងរកឲ្យធ្វើចំណាត់ប្រភេទឡើងវិញនូវរបាយការណ៍វិភាគ ដែលត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញាទេ ឬដែលត្រូវបានភ្ជាប់ជាឯកសារសំអាងផ្លូវច្បាប់ទៅនឹងសារណាជាច្រើននោះទេ។

### ៤. *អត្ថបទសារព័ត៌មាន (ផ្នែក II)*

91. ដូចបានពិភាក្សាខាងលើ[98] "អត្ថបទសារព័ត៌មាន" ទាំងអស់នេះមានកាលបរិច្ឆេទក្រោយសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ ភាគច្រើនរៀបរាប់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងភ្លាមៗក្រោយរបបបានបញ្ចប់ ចំណែកឯមួយចំនួនផ្សេងទៀត គឺជាបទសម្ភាសន៍សារព័ត៌មានក្រោយរបបកម្ពុជាប្រជាធិបតេយ្យដែលផ្តល់ដោយមេដឹកនាំជាន់ខ្ពស់។ ជាការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ទូទៅ ក្នុងការធ្វើឲ្យឯកសារទាំងនេះទៅជាសាធារណៈ ស.ព.អ ស្វែងរកឲ្យធ្វើចំណាត់ប្រភេទឡើងវិញឯកសារសម្ងាត់ចំនួន ៥៦ នៅក្នុងសំណុំរឿង ០០៤/២។ ទាំងអស់នេះមានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ឃ-៤ និងជាការកត់សម្គាល់រួមមានអត្ថបទទាក់ទងនឹង អោ អាន និង ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដូចជា ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ចាម។

### ៥. *បញ្ជីឯកសារ*[99]

92. ប្រភេទកំណត់ត្រានេះ មានបញ្ជីឯកសារចំនួនពីរប្រភេទ។ បញ្ជីទីមួយ គឺតារាងឯកសារច្បាប់យោងដែលបានដាក់ជាមួយនឹងសារណា និងផ្តល់សេចក្តីយោងពេញលេញសម្រាប់ឯកសារច្បាប់ និង

---

ក្នុងសំណុំរឿង ០០១), E3/2653, E3/2812, E3/2813, E3/2817 (E160.1 ក្នុងសំណុំរឿង ០០១), E3/2818, E3/3304, E3/3346, E3/3555, E3/4202, E3/9686, E3/10655, E131/1/13.12, E285.1.1។

[98] *សូមមើល* ផ្នែក V.ក.៩ *យោងខាងលើ*។

[99] *សូមមើល* ជើងទំព័រ ៤២ *យោងខាងលើ* (កត់សម្គាល់ថា បញ្ជីឯកសារមួយចំនួនមាននៅក្នុងឧបសម្ព័ន្ធ ខ ចំណែកឯបញ្ជីដែលនៅសល់មាននៅក្នុងឧបសម្ព័ន្ធ ឃ-៥ និងពន្យល់ពីមូលហេតុសម្រាប់ការបែងចែកនោះ)។

ឯកសារផ្សេងទៀត ដែលភាគីបានដកស្រង់នៅក្នុងសារណា ដើម្បីគាំទ្រអំណះអំណាងច្បាប់ និងអង្គហេតុរបស់ខ្លួន។ ដូចបានពិភាក្សានៅកន្លែងផ្សេងទៀតក្នុងសំណើនេះ ស.ព.អ ផ្តល់អនុសាសន៍ថា តារាងឯកសារច្បាប់យោង គួរត្រូវធ្វើចំណាត់ប្រភេទឡើងវិញឱ្យទៅជាសាធារណៈ ប៉ុន្តែរក្សាទុកឯកសារច្បាប់យោងជាមូលដ្ឋានទាំងនោះជាសម្ងាត់[100]។

93. បញ្ជីទីពីរគឺជាបញ្ជីលម្អិតនៃឯកសារដែលបានបន្ថែម (ឬស្នើសុំដាក់បន្ថែម) ទៅក្នុងសំណុំរឿង ឬពាក់ព័ន្ធទៅនឹងសារណា (ហើយហេតុដូច្នេះ អាចមានសេចក្តីសង្ខេប ឬអំណះអំណាងពាក់ព័ន្ធនឹងឯកសារនីមួយដែលបានរៀបរាប់ក្នុងបញ្ជី[101])។ ស.ព.អ ផ្តល់អនុសាសន៍ថាប្រភេទបញ្ជីឯកសារនេះនៅបន្តជាសម្ងាត់ ដោយសារតែវាជាញឹកញាប់មានព័ត៌មានដែលចាំបាច់ត្រូវមានការការពារ ដូចជាឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក្យសុំរបស់ខ្លួនមិនត្រូវបានទទួលយក។

94. ក្នុងសំណុំរឿង ០០៤/២ ស.ព.អ ស្នើសុំការធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារសម្ងាត់ចំនួន ២៧៤ ក្នុងចំណោមឯកសារសម្ងាត់ចំនួន ៦៣៥។ ឯកសារមួយចំនួន គឺជាតារាងសំអាងផ្លូវច្បាប់ដែលបានដាក់ជាមួយនឹងសារណា ដែលត្រូវបានធ្វើឱ្យទៅជាសាធារណៈរួចហើយនៅក្នុងសំណុំរឿង ០០៤/២ (ដូចបានចែងក្នុង ឧបសម្ព័ន្ធ ឃ-៥) ខណៈឯកសារដែលនៅសល់ត្រូវបានដាក់តាមក្រុមជាមួយសារណាពាក់ព័ន្ធ ដែលបាននិងកំពុងស្នើឱ្យធ្វើទៅជាសាធារណៈក្នុងសំណើរនេះ(ឧបសម្ព័ន្ធ ខ)។

## ខ. ចម្លើយ និង តំណាងសក្ខីកម្ម

95. ប្រភេទកំណត់ត្រាដែលមាននៅក្នុងប្រភេទដ៏ទូលំទូលាយនេះមាន (១) ចម្លើយរបស់ជនសង្ស័យ (២) ប្រតិចារឹក (៣) ចម្លើយសាក្សី (៤) កំណត់ហេតុស្តាប់ចម្លើយ (៥) ពាក្យសុំរបស់ជនរងគ្រោះ និង (៦) ឯកសាររបស់ជនរងគ្រោះ[102]។ សម្ភារទាំងអស់នេះដើរតួនាទីសំខាន់ក្នុងការជួយបញ្ជាក់ការពិតអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែឯកសារ

[100] *សូមមើល* កថាខណ្ឌ ៤២ *យោងខាងលើ*។

[101] ជាឧទាហរណ៍ វាអាចរៀបរាប់អំពីចម្លើយសាក្សី ដែលភាគីមួយក្នុងចំណោមភាគីទាំងឡាយអះអាងថា មិនអាចទទួលយកបាន ពីព្រោះអ្នកស៊ើបអង្កេត ក.ស.ច.ស បានប្រើប្រាស់បច្ចេកទេសសួរលម្អៀងនៅពេលស្តាប់ចម្លើយសាក្សីទាំងនោះ។ បន្ថែមលើការផ្តល់លេខឯកសារ ចំណងជើង កាលបរិច្ឆេទ និង លេខ ERN នៃចម្លើយសាក្សីដែលអាចជំទាល់បានទាំងនោះ "បញ្ជីឯកសារ" ក៏អាចមានសេចក្តីដកស្រង់ពីចម្លើយដែលបានចោទថាបង្ហាញពីភាពលម្អៀងផងដែរ។

[102] សម្រាប់គោលបំណងវិភាគ ចម្លើយសាក្សី និងកំណត់ហេតុស្តាប់ចម្លើយ ត្រូវបានបញ្ចូលគ្នាជា "សម្ភាររបស់សាក្សី" និងពាក្យសុំរបស់ជនរងគ្រោះ និងឯកសារជនរងគ្រោះ ត្រូវបានដាក់ជាក្រុមរួមគ្នានៅក្នុង "សម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ"។

ទាំងនេះផ្តល់នូវការរៀបរាប់ដំបូងអំពីព្រឹត្តិការណ៍។ វាក៏ផ្តល់ភ័ស្តុតាងអំពីឋានានុក្រម និងរចនាសម្ព័ន្ធទំនាក់ទំនងរបស់ ប.ក.ក ការសម្របសម្រួលផ្នែកភស្តុភារដែលពាក់ព័ន្ធ ក្នុងចំណោមបណ្តាញមន្ទីរសន្តិសុខ និងគម្រូដែលបង្ហាញពីលក្ខណៈជាប្រព័ន្ធ និងរីករាលដាល និង/ឬ ចេតនា នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ ជាវិបាក ឯកសារទាំងនេះមានសារសំខាន់ទាំងសម្រាប់គោលបំណងភ័ស្តុតាង និងទាំងសម្រាប់គោលបំណងប្រវត្តិសាស្ត្រ។

96. ស្ថិតក្រោមករណីលើកលែងមួយចំនួនដូចបានកត់សម្គាល់ខាងក្រោម ស.ព.អ ផ្តល់អនុសាសន៍ថា ចម្លើយ និងភ័ស្តុតាងសក្ខីកម្មទាំងអស់នេះត្រូវធ្វើឲ្យទៅជា **សាធារណៈ** ប៉ុន្តែធ្វើទៅបានបន្ទាប់ពីមានការពិនិត្យយ៉ាងប្រុងប្រយ័ត្ន ហើយព័ត៌មានរសើប និងព័ត៌មានឯកជនត្រូវបានកោសលុប[103]។ ការធានាថា សម្ភារទាំងអស់នេះត្រូវបានធ្វើឲ្យទៅជាសាធារណៈតាមដែលអាចបាន នឹងអនុញ្ញាតឲ្យជំនាន់ក្រោយ និងអ្នកស្រាវជ្រាវយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិរបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍ និងបទចោទនានាក្នុងសំណុំរឿងទាំងអស់នេះ ខណៈដែលការកោសលុបនឹងរក្សាបាននូវសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលដែលបានចូលរួមយ៉ាងអង់អាចក្នុងដំណើរការរបស់ អ.វ.ត.ក[104]។

## ១. *ចម្លើយរបស់ជនសង្ស័យ*

97. កំណត់ត្រាប្រភេទនេះ មានចម្លើយដែលធ្វើឡើងដោយអតីតមន្ត្រីរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី, នួន ជា, ខៀវ សំផន, កាំង ហ្កេកអ៊ាវ ហៅ ឌុច, អោ អាន, និង អ៊ឹម ចែម។ ចម្លើយទាំងនេះស្ថិតក្នុងប្រភេទចំនួនបី៖ មួយចំនួនបានធ្វើជាសាធារណៈនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មួយចំនួនបានបង្កើតឡើងនៅក្រោយរបបនេះដួលរលំ ប៉ុន្តែមុនពេលអ្នកនិយាយនោះក្លាយជាជនសង្ស័យរបស់ អ.វ.ត.ក និងមួយចំនួនត្រូវបានធ្វើឡើងបន្ទាប់ពីអ្នកនិយាយបានដឹងថាគាត់គឺជាជនសង្ស័យ ឬជនត្រូវចោទរបស់ អ.វ.ត.ក។ ដោយសារតែចម្លើយទាំងអស់នេះត្រូវបានធ្វើឡើងដោយអតីតមេដឹកនាំ ពួកវាផ្តល់នូវទស្សនៈសំខាន់ និងពិសេសអំពីព្រឹត្តិការណ៍ដែលបានកើតឡើង។ មិនមានចម្លើយណាក្នុងចំណោមចម្លើយទាំងអស់នេះមានព័ត៌មានដែលចាំបាច់ត្រូវបន្តការការពារទៀតនោះទេ។

98. អនុលោមតាមគោលការណ៍ទូទៅក្នុងការធ្វើឲ្យចម្លើយ និងភ័ស្តុតាងសក្ខីកម្មទាំងនេះជាសាធារណៈ ស.ព.អ ស្នើឲ្យធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារសម្ងាត់ទាំងអស់ចំនួន ៩០ នៅក្នុងប្រភេទកំណត់ហេតុនេះក្នុងសំណុំរឿង ០០៤/២ ដូចមានបង្ហាញនៅក្នុងឧសម្ពន្ធ ង-១។ ឧបសម្ពន្ធក៏កំណត់

---

103 *សូមមើល* កថាខណ្ឌ ៤, ២២-២៤ និងជើងទំព័រ ៩៥ *យោងខាងលើ*។

104 ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៥ *យោងខាងលើ*។

អត្តសញ្ញាណផងដែរនូវចម្លើយណាដែលជាសាធារណៈរួចហើយក្នុងសំណុំរឿង ០០១ និង/ឬ សំណុំរឿង ០០២ និងលេខឯកសារពាក់ព័ន្ធរបស់ពួកវា។

## ២. *ប្រតិចារឹក*

99. សម្ភារនៅក្នុងប្រភេទកំណត់ហេតុនេះរួមមាន ប្រតិចារឹកនៃការជំនុំជម្រះជាសាធារណៈរបស់ អ.វ.ត.ក ប្រតិចារឹកសវនាការ អ.វ.ត.ក ដែលធ្វើឡើងដោយសម្ងាត់ ប្រតិចារឹកការស្តាប់ចម្លើយរបស់ ក.ច.ស.ស ប្រតិចារឹកបទសម្ភាសន៍ដោយ DC-Cam ប្រតិចារឹកបទសម្ភាសន៍ដែលផ្តល់ឱ្យដោយជនភៀសខ្លួនកម្ពុជាភ្លាមៗក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ កម្រងសំណួររបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា (ស៊ី.ឌី.ភី) ដែលបានបំពេញ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងប្រតិចារឹកវីដេអូឯកសារទាក់ទងនឹងខ្មែរក្រហម។ ស្ថិតក្រោមករណីលើកលែងមួយចំនួន ស.ព.អ យល់ឃើញថា ប្រតិចារឹកទាំងនេះគួរធ្វើឱ្យទៅជាសាធារណៈ។

100. ទោះជាយ៉ាងណា ស.ព.អ ផ្តល់ជាអនុសាសន៍ថា អង្គជំនុំជម្រះគួរប្រើវិធីសាស្ត្រហ្មត់ចត់ជាងមុនជាមួយនឹងប្រតិចារឹកស្តាប់ចម្លើយរបស់ ក.ស.ច.ស និង DC-Cam ដោយសារឯកសារទាំងអស់នេះអាចមានព័ត៌មានទំនាក់ទំនង ឬព័ត៌មានឯកជនផ្សេងទៀតដែលតម្រូវឱ្យមានការកោសលុប មុនពេលធ្វើឱ្យឯកសារទាំងនោះអាចចូលមើលបានជាសាធារណៈ[105]។ ស.ព.អ ក៏កត់សំគាល់ផងដែរថា DC-Cam មានគោលការណ៍ស្តីពីលទ្ធភាពចូលមើលឯកសារមួយចំនួន ដែលស្ថិតក្រោមសមូហកម្មរបស់ខ្លួន ដូច្នេះ អ.វ.ត.ក ចាំបាច់ត្រូវឱ្យប្រាកដថា ខ្លួនមិនបំពានលើគោលការណ៍ទាំងនេះ។ ស.ព.អ លើកទឹកចិត្តឱ្យអង្គជំនុំជម្រះស្វែងរកធាតុចូលពីភាគីនានាលើបញ្ហាទាំងអស់នេះ ប៉ុន្តែទោះក្នុងករណីណាក៏ដោយ ឯកសារ អ.វ.ត.ក និង DC-Cam ត្រូវមានការពិនិត្យដោយប្រុងប្រយ័ត្នដើម្បីឱ្យប្រាកដថា ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានរសើប និងព័ត៌មានដែលមានការការពារ ត្រូវបានកោសលុបជាមុនសិនមុននឹងធ្វើឱ្យឯកសារទាំងនោះទៅជាសាធារណៈ។

101. ក្នុងសំណុំរឿង ០០៤/២ ស.ព.អ ស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារសម្ងាត់ចំនួន ៩៥៧ ក្នុងចំណោមឯកសារសម្ងាត់ចំនួន ២.៣៩៥។ ឯកសារទាំងអស់នេះរួមមានប្រតិចារឹកជំនុំជម្រះជាសាធារណៈពីសំណុំរឿង ០០១ និង ០០២[106] បទសម្ភាសន៍ DC-Cam ជាមួយ អោ

---

[105] *សូមមើល* កថាខណ្ឌ ៤-៥, ២២-២៤ ជើងទំព័រ ៤៥ *យោងខាងលើ*។

[106] ស.ព.អ កត់សម្គាល់ថា ប្រតិចារឹកជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ មួយចំនួន ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងកែតម្រូវមិនត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងសំណុំរឿង ០០៤/២ ទេ។ គាត់យល់ឃើញថា ការណ៍នេះគួរត្រូវបានធ្វើមុនពេលដែលឯកសារ

អាន និង អ៊ុម ចែម កម្រងសំណួររបស់ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ( ស៊ី.ឌី.ភី ) ដែលបានបំពេញ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ (ដោយបានដកចេញព័ត៌មានអត្តសញ្ញាណ) និងប្រតិចារឹកបទសម្ភាសន៍ជនភៀសខ្លួន។ ស.ព.អ ស្នើសុំផងដែរឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញនូវប្រតិចារឹកពីអំណះអំណាងផ្ទាល់មាត់ក្នុងសំណុំរឿង ០០៤/២ នៅចំពោះមុខ អ.ប.ជ។ ទោះបីជាសវនាការត្រូវបានធ្វើឡើងជាសម្ងាត់ មិនមានមូលហេតុណាត្រូវបន្តការសម្ងាត់ទៀតទេដោយសារតែខ្លឹមសារដែលបានពិភាក្សាត្រូវបានធ្វើឲ្យទៅជាសាធារណៈ នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ភាគី និងសេចក្តីពិចារណារបស់ អ.ប.ជ រួចទៅហើយ។ ស.ព.អ មិនស្វែងរកឲ្យមានការធ្វើចំណាត់ប្រភេទឯកសារនៅសេសសល់នៅក្នុងប្រភេទកំណត់ត្រានេះនៅពេលនេះទេ[107]។

## ៣. *សម្ភាររបស់សាក្សី*

102. សម្រាប់គោលបំណងនៃការវិភាគនេះ ស.ព.អ បានដាក់ជាក្រុមនូវប្រភេទកំណត់ហេតុជា "ចម្លើយសាក្សី" និង"កំណត់ហេតុស្តាប់ចម្លើយ"[108] រួមបញ្ចូលគ្នា ពីព្រោះគោលការណ៍នៃការធ្វើចំណាត់ប្រភេទដូចគ្នានេះអនុវត្តលើពួកវាទាំងពីរនេះ។ បន្ថែមលើចម្លើយដែលធ្វើដោយសាក្សីសក្ខីពល (និង ដើមបណ្តឹងរដ្ឋប្បវេណី) ទៅកាន់ ក.ស.ច.ស និង DC-Cam សម្ភារទាំងអស់នេះរួមមានការអង្កេតអំពីអំពើហិង្សាផ្លូវភេទ ចម្លើយ និងកំណត់សម្គាល់ធ្វើឡើងដោយជនសង្ស័យ អ.វ.ត.ក កំណត់ហេតុនៃកិច្ចស៊ើបសួរ សេចក្តីថ្លែងអំពីការបោះបង់សិទ្ធិមានវត្តមានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលស្តាប់ចម្លើយដោយ ក.ស.ច.ស និងកំណត់ត្រាសម្បថចូលកាន់តំណែងរបស់អ្នកបកប្រែផ្ទាល់មាត់ អ្នកបកប្រែសំណេរ និងសាក្សី។

---

ត្រូវបានធ្វើឲ្យទៅជាសាធារណៈនៅក្នុងសំណុំរឿង០០៤/២។ ដោយការប្រៀបធៀបជាអេឡិចត្រូនិកនូវទំព័រលេខយោង ERN និងឈ្មោះឯកសារសម្រាប់ប្រតិចារឹកនៅក្នុងរឿងក្តីទាំងពីរ អង្គជំនុំជម្រះអាចកំណត់អត្តសញ្ញាណ និងដាក់ជំនួសសំណៅដែលហួសកាលបរិច្ឆេទ។ ឧទាហរណ៍ ប្រសិនបើចំណងជើងឯកសារសម្រាប់ទំព័រ ERN ដូចគ្នា ចាប់ផ្តើមដោយ [កែតម្រូវលើកទី២] នៅក្នុងសំណុំរឿង ០០៤/២ និង [កែតម្រូវលើកទី៣] នៅក្នុងសំណុំរឿង ០០២/០២ នោះវាច្បាស់ណាស់ថា សំណៅក្នុងសំណុំរឿង ០០៤/២ គឺហួសកាលបរិច្ឆេទ និងគួរត្រូវបានជំនួសដោយ [កែតម្រូវលើកទី៣]។ របៀបផ្សេងទៀតដែលអាចដឹងថាតើប្រតិចារឹកណាមួយក្នុងសំណុំរឿង ០០៤/២ ហួសសម័យឬអត់ គឺថាតើប្រតិចារឹកឆ្លើយឆ្លងគ្នានៅក្នុងសំណុំរឿង ០០២ មានពាក្យ "old (ចាស់) ដែរឬទេនៅក្នុងលេខឯកសារ។ ក្នុងករណីជាច្រើន សំណៅ "ចាស់" នៅមាននៅក្នុងសំណុំរឿង ប៉ុន្តែសំណៅដែលបានធ្វើបច្ចុប្បន្នភាពក៏មាននៅទីនោះដែរ។ ស.ព.អ លើកបញ្ហានេះពាក់ព័ន្ធតែទៅនឹងប្រតិចារឹក ដែលមិនមានបញ្ហានេះប៉ុណ្ណោះ។ *សូមមើលឧទាហរណ៍* ឯកសារ **D179/1.2.13** (ប្រតិចារឹកភាសាអង់គ្លេស); ឯកសារ **D179/1.2.8** (ប្រតិចារឹកភាសាអង់គ្លេសនិងបារាំង),ឯកសារ **D219/702.1.6** (ប្រតិចារឹកគ្រប់ភាសាផ្លូវការទាំង៣) ឯកសារ **D289.5** (ប្រតិចារឹកភាសាអង់គ្លេសនិងបារាំង)។

[107] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ១០០ *យោងខាងលើ*។

[108] នេះជាការប្រកបពាក្យនៃប្រភេទកំណត់ហេតុនៅក្នុងសាយឡាប។

103. ដូចបានពិភាក្សាខាងលើទាក់ទងនឹងប្រតិចារឹកស្តាប់ចម្លើយ ក.ស.ច.ស និង DC-cam[109] ស.ព.អ យល់ឃើញថា អង្គជំនុំជម្រះចាំបាច់ត្រូវកំណត់ដំណើរការការធ្វើចំណាត់ប្រភេទឡើងវិញ ដែលខ្លួននឹងធ្វើទាក់ទងនឹងចម្លើយដែលបានផ្តល់ទៅឲ្យ ក.ស.ច.ស និង DC-Cam[110]។ ទាក់ទងនឹងឯកសារផ្សេងទៀតនៅក្នុងក្រុមនេះ ស.ព.អ រំលឹកឡើងវិញនូវអនុសាសន៍របស់ខ្លួនថា កំណត់ហេតុនៃកិច្ចស៊ើបសួរ ត្រូវស្ថិតនៅជាសម្ងាត់ដដែល[111]។ គាត់ក៏សន្និដ្ឋានដែរថា សេចក្តីថ្លែងអំពីការបោះបង់សិទ្ធិមានវត្តមានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសម្បថចូលរបស់បុគ្គលមួយចំនួនមានលក្ខណៈរដ្ឋបាលសុទ្ធសាធ និងមិនចាំបាច់តម្រូវឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញទេ។ ប្រសិនបើអង្គជំនុំជម្រះមិនឯកភាព ស.ព.អ កត់សម្គាល់ថា ឯកសារជាច្រើនដែលមានព័ត៌មានទាក់ទងផ្ទាល់ខ្លួនដែលគួរត្រូវកោសលុប មុនពេលពួកវាត្រូវបានធ្វើឲ្យទៅជាសាធារណៈ។ ជាងនេះទៀត សម្ភារណាដែលពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញ ប្រសិនបើ CPA ឬបណ្តឹងពាក់ព័ន្ធនោះជឿជាក់ថា ត្រូវបានទទួលយកដោយ ស.ច.ស.អ សម្រាប់រឿងក្តីនោះ[112]។

104. អនុវត្តគោលការណ៍ទាំងនេះនៅក្នុងសំណុំរឿង ០០៤/២ ស.ព.អ ស្វែងរកឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញនូវឯកសារសម្ងាត់ចំនួន ៣៩៤ ក្នុងចំណោមឯកសារសម្ងាត់ចំនួន ៦.២៦៣។ ឯកសារទាំងនេះមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ង-៣ និងរួមមាន ចម្លើយធ្វើឡើងដោយជនសង្ស័យនៃ អ.វ.ត.ក ការអង្កេតអំពីអំពើហិង្សាផ្លូវភេទ ដែលក្នុងនោះព័ត៌មានកំណត់អត្តសញ្ញាណទាំងអស់ត្រូវបានដកចេញ របាយការណ៍កំណត់អត្តសញ្ញាណទីតាំងជាក់លាក់ក្នុងសំណុំរឿង ០០៤/២ កំណត់ត្រា

[109] *សូមមើល* កថាខណ្ឌ ១០០ *យោងខាងលើ*។ អនុវត្តគោលការណ៍ និងកង្វល់ដូចគ្នានេះ។

[110] សម្រាប់មូលហេតុនេះ ស.ព.អ មិនស្នើធ្វើចំណាត់ប្រភេទឡើងវិញសម្រាប់ឯកសារទាំងអស់នេះ នៅក្នុងសំណុំរឿង ០០៤/២ នៅពេលនេះទេ។ ដូចបានពិភាក្សាក្នុងកថាខណ្ឌ១០០ ខាងលើ ស.ព.អ សូមផ្តល់អនុសាសន៍ឲ្យអង្គជំនុំជម្រះ ស្វែងរកធាតុចូលពីភាគីនានាមុនធ្វើចំណាត់ប្រភេទឡើងវិញលើកំណត់ហេតុដូច្នេះ ប៉ុន្តែទោះក្នុងករណីណាក៏ដោយ ឯកសារ អ.វ.ត.ក និង DC-Cam ត្រូវមានការពិនិត្យដោយប្រុងប្រយ័ត្នដើម្បីឲ្យប្រាកដថា ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានរសើប និងព័ត៌មានដែលមានការការពារត្រូវបានកោសលុបជាមុនសិន មុននឹងធ្វើឲ្យទៅជាសាធារណៈ។

[111] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ៤១ *យោងខាងលើ*។

[112] *សូមមើល* កថាខណ្ឌ ២២ *យោងខាងលើ*។ ឯកសារ **D362.1** ឧបសម្ព័ន្ធ ក៖ ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានប្រកាសថា អាចទទួលយកបាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ ឯកសារ **D362.3** ឧបសម្ព័ន្ធ គ៖ ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានពិចារណាថាជាបណ្តឹង ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ *សូមមើលផងដែរ* ឯកសារ **D362/6** សេចក្តីពិចារណារបស់ អ.ប.ជ លើភាពអាចទទួលយកបាន យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១១៨ (សម្រេចថា ដីការបស់ ស.ច.ស.អ លើភាពអាចទទួលយកបានមានសុពលភាព)។

ទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូង និងជាបន្តបន្ទាប់របស់ អោ អាន នៅចំពោះមុខ ស.ច.ស.អ និងសក្ខីកម្មមកពីវេទិកាសាធារណៈអំពីស្ត្រី ដែលពិភាក្សាអំពីអំពើហិង្សាផ្លូវភេទ។

## ៤. *សម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ*

105. ការវិភាគនេះដាក់ជាក្រុមនូវប្រភេទកំណត់ត្រា "ពាក្យសុំរបស់ជនរងគ្រោះ" និង "ឯកសាររបស់ជនរងគ្រោះ" រួមបញ្ចូលគ្នា ពីព្រោះគោលការណ៍នៃការធ្វើចំណាត់ប្រភេទដូចគ្នានេះអនុវត្តលើពួកវាទាំងពីរនេះ។ ទោះជាយ៉ាងណា ដូចបានលម្អិតខាងដើម សម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ អាចត្រូវបានគេយល់បានល្អបំផុត នៅពេលដែលត្រូវបានដាក់ជាក្រុមតាមលេខរាងជាមួយនឹងឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាឲ្យមានការអនុវត្តការកោសលុបស៊ីចង្វាក់គ្នា[113]។ សម្ភារទាំងអស់នេះអាចរួមមាន CPA ឬ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ("VIF") របាយការណ៍សង្ខេបខ្លឹមសារ CPA ឬ VIF លិខិតប្រគល់សិទ្ធិឲ្យមេធាវី ព័ត៌មានបន្ថែម និងសម្ភារផ្សេងទៀត ដូចជារូបថត ដែលបានផ្តល់ដោយជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី[114]។

106. ជាគោលការណ៍ទូទៅសម្រាប់ការស៊ើបអង្កេតរឿងក្តី ដែលមិនបានទៅដល់ការជំនុំជម្រះ CPA និងពាក្យបណ្តឹង ដែលត្រូវបានទទួលយកដោយ ស.ច.ស.អ (និងសម្ភារពាក់ព័ន្ធរបស់ពួកវា) គឺជាសម្ភារដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ដែលគួរត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញនៅក្នុងរឿងក្តីជាក់លាក់នោះ[115]។ សំខាន់បំផុតនោះ ឯកសារគួរត្រូវបានពិនិត្យយ៉ាងប្រុងប្រយ័ត្ន ដើម្បីឲ្យព័ត៌មានផ្ទាល់ខ្លួន និងមិនចង់ឲ្យគេដឹងឮ ឬដែលត្រូវការពារ ត្រូវបានកោសលុប មុនពេលឯកសារត្រូវបានធ្វើឲ្យទៅជាសាធារណៈ[116]។ ស.ព.អ បញ្ជាក់អង្គជំនុំជម្រះបន្ថែមទៀតអំពីគោលការណ៍ដែលបានពិភាក្សាដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២ ដែលបានលើកឡើងនូវបញ្ហាផ្សេងទៀតទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ នៅក្នុងរឿងក្តី

---

[113] ដូចបានពិភាក្សាក្នុងកថាខណ្ឌ ២៨ *យោងខាងលើ*។

[114] *សូមមើល* កថាខណ្ឌ ៤០-៤១, ៧៥, ៨៤-៨៥ *យោងខាងលើ* សម្រាប់អនុសាសន៍ជាក់លាក់របស់ ស.ព.អ លើប្រភេទផ្សេងទៀតនៃឯកសារ។

[115] *សូមមើលជាពិសេស* កថាខណ្ឌ ២២ *យោងខាងលើ*។ ក្នុងសំណុំរឿង ០០៤/២ ការណ៍នេះនឹងដកចេញការធ្វើចំណាត់ប្រភេទសម្ភារមួយចំនួនដែលបានសម្រេចថាអាចទទួលយកបានក្នុងសំណុំរឿង០០៤ ឬ០០៤/១ ពីព្រោះពួកវាមិនបំពេញបាននូវលក្ខខណ្ឌតម្រូវអប្បរមានៃភាពទទួលយកបានសម្រាប់សំណុំរឿង ០០៤/២។ គោលការណ៍បែបនេះ នឹងធានាថាព័ត៌មានដែលអាចការពារបានកាន់តែមាន និងមានសង្គតភាព។

[116] *សូមមើល* កថាខណ្ឌ ៤-៥, ២២-២៤ និងជើងទំព័រ ៤៥ *យោងខាងលើ*។

អ.វ.ត.ក ទាំងអស់ និងដែលសមនឹងទទួលបានការពិចារណាយ៉ាងយកចិត្តទុកដាក់ និងការអនុវត្តយ៉ាងប្រុងប្រយ័ត្ន[117]។

107. ការអនុវត្តគោលការណ៍ទាំងនេះ ស.ព.អ ស្នើឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញនូវសម្ភារសម្ងាត់របស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី ចំនួន ១.៦១៦ នៅក្នុងសំណុំរឿង ០០៤/២ ដូចដែលបានលម្អិតនៅក្នុងឧបសម្ពន្ធ ង-៤ ប៉ុន្តែ ទាល់តែក្រោយពេលមានកោសលុបសមស្របជាមុន។

## VI. សេចក្ដីសន្និដ្ឋាន

108. ស.ព.អ សង្ឃឹមថា សំណើនេះនឹងជួយក្នុងការកំណត់អត្តសញ្ញាណបញ្ហា និងការបង្កើតគោលការណ៍ដែលនឹងធានាដល់ដំណើរការនៃការធ្វើចំណាត់ប្រភេទឡើងវិញនៅ អ.វ.ត.ក ត្រូវបានអនុវត្តដោយការប្រុងប្រយ័ត្ន និងប្រកបដោយសង្គតិភាព។ ស.ព.អ ស្នើឲ្យអង្គជំនុំជម្រះធ្វើឲ្យទៅជាសាធារណៈនូវឯកសារដែលបានស្នើសុំសម្រាប់ការធ្វើចំណាត់ប្រភេទឡើងវិញក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីមានការអនុវត្តលើការកោសលុបចាំបាច់ណាមួយលើព័ត៌មានដែលត្រូវការពារ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[117] សំណុំរឿង ០០២-**F71** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំការសម្រេច។